# ការសម្ភាសរបស់លោកយាយ សេន គឹមវ៉េន

ក៖ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខ៖ អ្នកត្រូវគេសំភាសន៍ឈ្មោះ សេន គឹមវ៉េន

ក៖ ចាស សូមជំរាបសួរយាយ!!!

ខ៖ ចាសជំរាបចៅ!!!

ក៖
ចាសលោកយាយថ្ងៃនេះចៅសុំសួរលោកយាយព្រោះថ្ងៃនេះចៅមានឪកាសដើម្បីសំភាសន៍លោកយាយផ្ទាល់ហើយចៅនឹងរក្សាសំលេងរបស់លោកយាយដើម្បីទុកអោយកូនចៅជំនាន់ក្រោយគេបានស្តាប់សំលេងលោកយាយនៅថ្ងៃនេះហើយចៅនឹងរក្សាវាទុកអោយទៅសាលាខាងសហរដ្ឋអាមេរិកសំរាប់ថ្ងៃនេះដែលចៅបានសំភាសន៍លោកយាយ
ហើយអោយគេយកទៅដាក់ក្នុងវេបសាយនឹងដើម្បីអោយកូនចៅជំនាន់ក្រោយគេមានឪកាសក្នុងការស្តាប់សំលេងរបស់លោកយាយផ្ទាល់
ហើយពួកគាត់នឹងអាចស្តាប់អំពីប្រវត្តិរបស់លោកយាយ
អំពីជីវប្រវត្តិរបស់លោកយាយនឹងរឿងរាវផ្សេងៗដែលទាក់ទង់នឹងជីវិតរបស់លោកយាយតែម្តងជាងពិសេសកូនចៅរបស់លោកយាយផ្ទាល់គាត់អាចនឹងបានស្តាប់សំលេងរបស់លោកយាយ។

ហើយដូចនេះហើយតើលោកយាយអនុញ្ញាតដើម្បីអោយខ្ញុំបានសំភាសន៍លោកយាយនៅថ្ងៃនេះដែលឬទេ?

ខ៖ ចាស អនុញ្ញាត។

ក៖
ចាសអរគុណលោកយាយចឹងជាដំបូងចៅសុំសួរឈ្មោះលោកយាយមានឈ្មោះអ្វីដែលលោកយាយ?

ខ៖ ឈ្មោះសេន គឹមវ៉េន។

កៈ ចាស ចឹងឈ្មោះលោកយាយសេន គឹមវ៉េនត្រូវជាមួយនឹងអត្តសញ្ញាណប័ត្រដែលឬទេលោកយាយ?

ខៈ ត្រូវ!

កៈ ចាសចុះលោកយាយនៅឆ្នាំនេះលោកយាយមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ អាយុ៦៩ឆ្នាំហើយ។

កៈ ចាស លោកយាយមានអាយុ៦៩ឆ្នាំហើយ។

ខៈ ចាស!!!

កៈ ហើយលោកយាយមាននៅចាំថ្ងៃខែឆ្នាំរបស់ខ្លួនឯងដែលឬទេ?

ខៈ អត់មានបានចាំទេព្រោះកាលនៅជំនាន់នឹងចាស់ៗប្រាប់ដែលប៉ុន្តែខ្ញុំបានភ្លេចអស់ហើយ។

កៈ ចាស! ចុះលោកយាយមានទីលំនៅកំណើតនៅឯណាដែលលោកយាយ?

ខៈ មានទីលំនៅឯស្រុកកំណើតនៅឯភូមិព្រៃកក្របៅ ឃុំព្រៃកក្របៅ ស្រុកកងមាស ខេត្តកំពុងចាម។

កៈ ចាស! ចឹងចុះលោកយាយមានបានធ្លាប់ផ្លាស់ប្តូរទីលំនៅដែរឬទេ?

ខៈ ចាស! ធ្លាប់បានផ្លាស់ទីលំនៅដែលការពីជំនាន់ ដាច់អាពត ព្រោះកាលនឹងយាយបានផ្លាស់ទីលំនៅពីភូមិព្រៃកក្របៅ មកនៅ ភូមិពាមក្នុង។

កៈ ចាស!!!

ខៈ នៅក្នុងស្រុកកងមាសដែលកាលនឹង។

កៈ ចាស!ចឹងកាលនឹងលោកយាយបានផ្លាស់មកនៅក្នុងឆ្នាំណាដែល?

ខៈ កាលនឹងបានផ្លាស់មកនៅក្នុងសម័យសាធារណរដ្ឋនឹងហើយក៏បានដាច់មកនៅជំនាន់ពពតនឹងក៏បានចេញពីជំនាន់ចាស់មកចេញមកនៅតាមផ្លូវជាតិនឹងហ៎។

ក៖ ចាស៎ ហើយសព្វថ្ងៃនឹងលោកយាយមានមុខរបរជាអ្វីដែលលោកយាយ?

ខ៖ អូ៎ សព្វថ្ងៃនឹងយាយគ្មានមុខរបរអ្វីធំដូចជាគេទេយាយគ្រាន់តែមានមុខរបរបន្តិចបន្តួចសំរាប់ទុកចិញ្ចឹមកូន ហើយចេញពីនឹងមកចូលរបស់ថ្មីរកស៊ីលក់នំនិងធ្វើនំធ្វើអីចឹងទៅសំរាប់ចិញ្ចឹមកូនទៅ។

ក៖ ចាស៎ចឹង ហើយតើលោកយាយមានកូនប៉ុន្មាននាក់ដែរ?

ខ៖ យាយមានកូនចំនួន៨នាក់ចៅ។

ក៖ ចាស៎ លោកយាយសព្វថ្ងៃនៅមានកូនចំនួន៨នាក់ចឹងតើលោកយាយមាននៅចាំឈ្មោះរបស់ពួកគាត់ដែលឬទេ?

ខ៖ ហែសមិនចាំ ចាំតើកូនបងគេឈ្មោះកុយ សុភាព កូនទី២ហៅថាឈ្មោះកុយសុភី ទី៣កុយសុភ័ណ្ឌ ទី៤កុយសុកល កូនទី៥ឈ្មោះកុយចេក ទី៦កុយ សៅ ទី៧កុយពុធ្ធា ទី៨កុយរស់ គឺជាកូន៣៧គេចប់ត្រឹមកូន៣៧នឹង។

ក៖ ចាស៎ ចឹងចំនួនកូនទាំ៨នាក់នឹងថាតើលោកយាយមានបានរៀបចំអោយកូនរៀបអាពាហ៌ពិពាហ៌កូនណាខ្លះហើយ?

ខ៖ ទឹមតែបាន៣ មើលបាន៤។

ក៖ ចាស៎យាយរៀបបានកូន៤នាក់ហើយ។

ខ៖ នឹងហើយបាន៤នាក់ចៅណាយាយមានកូនទាំងអស់ចំនួនបានតែប៉ុណ្ណឹងដែលបានរៀបការរួចនោះណាចៅ។

ក៖ ចុះលោកយាយតើកូនលោកយាយទាំង៤នាក់នឹងមានឈ្មោះអ្វីខ្លះដែរដែលលោកយាយបានរៀបចំអាពាហ៌ពីពាហ៌អោយ?

ខ៖ កូនយាយនឹងមានឈ្មោះថាកុយ សុភី កុយ សុភ័ណ្ឌ កុយ សៅ នឹងកុយ ពុធ្ធា។

ក៖ ចាស!ចឹងឥឡូវនឹងលោកយាយបានចៅៗហើយ?

ខ៖ បានចៅហើយមួយនាក់បានចៅខ្លះ៣ខ្លះទៅ៤ខ្លះទៅ២អីក៏មានដែល។

ក៖ ចាស!ហើយលោកយាយ...

ខ៖ ហើយខ្លះទៅបាន១។

ក៖ ចាស!
ហើយលោកយាយអើតើពួកគាត់ទាំងអស់គ្នាមានទីលំនៅនៅឯណាខ្លះដែរលោកយាយ?

ខ៖ អូ!!! ពួកគេនឹងទៅនៅឆ្ងាយៗណាស់ព្រោះគេចេញទៅរកស៊ី
ដូចខ្លះទៅគេទៅនៅឯស្រុកចំការលើទៅ មួយទៅនៅឯភ្នំពេញទៅ
ហើយមួយទៀតនៅឆ្ងាយណាស់
ហើយមួយទៀតនឹងគេបានទៅនៅជាមួយហើយបានធ្វើការទៅ។

ក៖
ចុះកូនចៅលោកយាយមានអ្នកដែលបានទៅនៅក្រៅស្រុកឬប្រទេសក្រៅដែលពួកគាត់ឥឡូវជាអានិជនចំលាស់ស្រុកដែរទេលោកយាយ?

ខ៖ មានទៅធ្វើការងារអោយគេជាពលករនឹងលក់ពលកម្មអោយគេមួយ។

ក៖ ចាស! គាត់បានទៅធ្វើជាពលករគេមួយនៅឯណាដែលលោកយាយ?

ខ៖ កូនយាយមានម្នាក់នឹងគេនៅឯប្រទេសកូរ៉េឯណោះណាចៅ។

ក៖
ចាស!ហើយលោកយាយមានកូនចៅណាផ្សេងដែលគាត់កំពុងតែរស់នៅប្រទេសក្រៅដែលឬទេ?

ខ៖
អូ!!!មានមួយទៀតដែលខ្ញុំបានអោយទៅរៀបការនឹងជនជាតិកូរ៉េហើយខ្ញុំនឹងមកលើកអោយទៅគេខាងឯកូរ៉េនឹងមួយដែរ គឺអោយទៅជនជាតិកូរ៉េមួយដែលនឹងស្រី។

ក៖ តើគាត់មានឈ្មោះអ្វីដែលលោកយាយ?

ខ៖ ឈ្មោះកុយ សៅ។

ក៖ ចាស!ហើយសព្វថ្ងៃនឹងតើគាត់មានកូនហើយឬនៅ?

ខ៖ ចាស!កូនខ្ញុំនឹងគេមានកូនចំនួន២នាក់ហើយ។

ក៖ ចាស!គាត់មានកូនចំនួន២នាក់ហើយ
ហើយតើលោកយាយមានបានចាំឈ្មោះចៅទាំង២នាក់នឹងដែរឬទេ?

ខ៖ អូ!!!ចៅទាំង២នាក់នឹងគេមានឈ្មោះថា ជូ ហាន់នី
ហើយមួយវិញទៀតគេមានឈ្មោះថាម៉េង អ៊ុក។

ក៖ ចាស! ហើយតើគាត់មានបានធ្លាប់បានមកលេងលោកយាយដែរឬទេ?

ខ៖ គេធ្លាប់បានមកលេងនៅស្រុកខ្មែរនឹងចំនួន២ដងហើយចៅ។

ក៖ ចាស! ហើយចុះលោកយាយមានបានធ្លាប់ទៅលេងគាត់វិញដែលឬទេ?

ខ៖
យាយនឹងបានធ្លាប់បានទៅលេងកូននឹងចៅបាន១ដងដែរកាលនឹងយាយបានទៅលេងប្រទេសកូរ៉េនឹងដោយសារកូប្រសារនឹងកូនសៅស្រីយាយនឹងគេបានធានាយាយទៅលេងចៅនឹងក្រុមគ្រួសារគេនៅឯខាងប្រសារនឹងណាចៅ។

ក៖ ចាស! ចឹងលោកយាយមានបានចាំតំបន់ដែលគាត់កំពុងតែរស់នៅដែលឬទេ?
ខ៖
អូ!!!យាយកាលនឹងបានភ្លេចបាត់ទៅហើយចៅអើយកាលនឹងមិនបានដឹងថាតំបន់ដែលគេកំពុងតែរស់នៅនឹងមានឈ្មោះអ្វីដែរទេ។ អត់ទេយាយមិនបាននៅចាំទេ។

កៈ ចាស!ផ្ទះនឹងវានៅឆ្ងាយពីទីរួមក្រុងលោកយាយ?

ខៈ អើ!!ដូចជានេះដែលប្រហែលជាចឹងហើយនៅឆ្ងាយដែលនឹង។

កៈ ដូចជានៅសេអ៊ូលមែនទេលោកយាយ?

ខៈ
មិនមែនទេគេនៅឆ្ងាយជាងព្រោះនៅកន្លែងនឹងនោះវានៅដល់ខេត្តហើយនឹងមិនបាច់និយាយច្រើនពីរឿងនឹងទេ។

កៈ ចាស!តំបន់នេះទេដឹងព្រោះខ្ញុំបានលឺអ៊ី។

ខៈ ខេត្តតេកូលគេនោះមិនដឹង។

កៈ ចាស!ប្រហែលជាតំបន់តេកូល។

ខៈ នឹងហើយប្រហែលជាតំបន់នឹងហើយ។

កៈ
ចាស!ហើយលោកយាយមានកូន៨នាក់ហើយចឹងតើសព្វថ្ងៃនឹងតើលោកយាយបានប្រកបមុខរបរន៉លោកយាយ?

ខៈ ចាស!យាយមានមុខរបរលក់នំអីខ្លះតិចតួចនឹង។

កៈ តើលោកយាយមានមុខរបស់អ្វីខ្លះដែល?

ខៈ យាយបានធ្វើនំត្នោត ហើយពេលខ្លះទៅក៏មានធ្វើជានំបាញ់អូលដែលចឹងទៅ
អន្សំអីចឹងដែលថៅ។

កៈ ចាស! ឃើញថាលោកយាយពិតជាពូកែមែនទែន ក្នុងការធ្វើនំធ្វើអីលោកយាយ។

ខៈ ចាស!

កៈ
ហើយកាលនឹងតើលោកយាយចេះធ្វើនំទាំងអស់នឹងពីណាដែលតើលោកយាយបានទៅរៀន
ជាមួយនឹងចាស់ៗឬក៏លោកយាយបានកាលនឹងតែពីខ្លួនឯងទេ?

ខៈ
អូកាលនឹងយាយរៀនចេះខ្លួនឯងទេគ្មាននរណាគេមកបង្រៀងយាយទេយាយត្រូវចេះធ្វើខ្លួន
ឯងតែម៉ង់នឹង
ព្រោះបើមិនចេះធ្វើហើយយកទៅលក់ចឹងតើបានលុយណាទៅទិញអីគេហូបបើយើងមានផ្ទះ
នៅខាងមុខផ្សារហើយនឹងអាចបានសំរាប់លក់ដូរហើយនឹង។
ហើយពេលដែលចេញមកនឹងបានលក់មុខរបរធ្វើនំនឹងហើយបានជាយាយនឹងអាចចិញ្ចឹមកូន
ទាំង៨នាក់នឹងបានបើមិនចឹងទេអត់បាយជាមិនខាតទេ
ហើយយាយកាលនឹងចិញ្ចឹមកូននឹងបានទាំង៨នាក់នឹងដល់រហូតទៅគេបានបែកបាក់គ្នាទៅមា
នរបររកស៊ីលក់ដូរអីហើយនឹង។
ហើយយាយបានលក់ដូរនេះនៅភូមិតូចនឹងហើយបានចិញ្ចឹមខ្លួន
ឯងបានទៀតនៅភូមិតូចមួយនឹង។

កៈ ចាស!ហើយលោកយាយបានលក់ដូរនឹងនៅឯផ្សារពាមក្នុងនេះផ្ទាល់ទេម្តង?

ខៈ ចាស!

កៈ
ហើយចឹងលោកយាយបានប្រកបមុខរបរនេះអស់រយះពេលប៉ុន្មានឆ្នាំហើយដែរទៅលោកយា
យ?

ខៈ យាយបានប្រកបមុខរបរនេះឡើងយូរដែលហើយនឹង
មើលតាំងពីដាច់របបពពតខ្មែរក្រហមនឹងមក
ហើយបានចេញពីព្រៃកក្រចៅនឹងមកហើយមកនៅពាមក្នុងវិញនឹងយាយបានសំរេចចិត្តធ្វើការ
លក់ដូរនំនេះវាឡើងអស់រយះពេលយូរដែលហើយមើលតាំងពី១៩៨៥ដល់ឆ្នាំ១៩៨៦អីម៉េច
ហើយនឹង។
ដល់ពេលដែលចេញមកបានមកធ្វើការងារនឹងមុខរបរនឹងទៅលក់ដូរនៅផ្សារនឹងវាយូរហើយ

ប្រើពេលក៏យូរណាស់ដែលនឹងតាំងពីចេញពីព្រៃកក្របៅនឹងហើយប្ដីឡើងមានជំងឺ ឈឺខ្លាំងហើយទៅពេទ្យអីដែលតែវាមិនបានបាត់អស់ដល់ចឹងហើយបានជាត្រូវសំរេចចិត្តធ្វើនំ ពេលដែលយាយនឹងនៅតែឯងជាស្ត្រីមេម៉ាយនឹងពេលដែលគាត់បានស្លាប់ទៅនឹង។

ក៖ ចាស! ក្រុមគ្រួសារលោកយាយឬក្រុមគ្រួសារនរណាដែរលោកយាយ?

ខ៖
ក្រុមគ្រួសារយាយនឹងដែលត្រូវជាប្ដីយាយនឹងគាត់បានស្លាប់ទៅហើយយាយនឹងបាននៅតែ ឯងជាមួយកូនៗដល់ទៅ៨នាក់ហើយរកស៊ីដើម្បីចិញ្ចឹមកូនៗនឹងដោយការធ្វើនំលក់នឹងណាចៅ ។

ក៖ ចាស! អូក្រុមគ្រួសារត្រូវជាស្វាមីរបស់លោកយាយនឹងផ្ទាល់តែម្ដង?

ខ៖ ចាស!នឹងហើយ។

ក៖ ចាស!តើស្វាមីរបស់លោកយាយមានឈ្មោះអ្វីដែល?

ខ៖ គាត់មានឈ្មោះថាលោកតាកុយ។

ក៖ ចាស!គាត់មានឈ្មោះថាលោកតាកុយ។

ខ៖ ចាស!ត្រូវហើយចៅ។

ក៖ ចាស!ចឹងហើយតើឪពុកម្ដាយរបស់លោកតាកុយមានឈ្មោះអ្វីដែរ?

ខ៖ អើ!!!ម្ដាយឪពុកគាត់អេស ម្ដាយគាត់មានឈ្មោះថាយាយថៃ
ឪពុកគាត់វិញមានឈ្មោះថាតាមី ប៉ុន្តែជាអាកុសលអីពួកគាត់បានស្លាប់បាត់
ហើយគាត់ទាំងពីរនាក់នឹងពួកគាត់បានបាត់បង់ជីវិតអស់ហើយ។

ក៖ តើពួកគាត់ស្លាប់ដោយសារមូលហេតុអ្វីដែលលោកយាយ?

ខ៖
ឪពុករបស់គាត់បានស្លាប់តាំងពីនៅក្នុងជំនាន់ពពតឯនោះរីឯម្ដាយគាត់វិញបានស្លាប់ទៅតាំង ពីគាត់នៅពីតូចមេសហើយកាលនឹងគាត់នៅតូចៗពេលដែលម្ដាយគាត់បានស្លាប់នោះ។

កៈ ចាស!
ហើយកាលនឹងលោកយាយនឹងលោកតាកុយតើកាលនឹងបានស្រលាញ់គ្នាឬឪពុកម្តាយជាអ្នកទុកដាក់អោយ?

ខៈ ហេស!!
កាលនឹងចាស់ៗខាងម្តាយយាយនឹងហើយចាស់ៗខាងគាត់នឹងបានផ្សំផ្គុំអោយយាយនឹងគាត់បានរៀបអាពាហ៍ពិពាហ៍អោយទេយាយនឹងគាត់កាលនឹងមិនបានស្រលាញ់គ្នាអីផងកាលនឹងនោះស្រាប់តែចាស់ៗគាត់រៀបអោយ
ហើយពេលនឹងក៏យាយនឹងបានថាចឹងស្រោចតែចាស់ៗទៅបើពួកគាត់ផ្សំផ្គុំអោយហើយនឹងក៏យកគ្នាជាប្តីប្រពន្ធទៅចៅ។
ព្រោះពេលនឹងណាគាត់នឹងបាននៅជាមួយនឹងជីតាហើយគាត់បានមកផ្សំផ្គុំអោយយាយនឹងកុងឯងនឹងតែម្តងទៅណា។

កៈ ចាស!ចឹងលោកយាយកាលនឹងនៅជាមួយខាងប្រុសក៏នៅជាមួយខាងស្រីដែរ?

ខៈ
កាលនឹងគាត់បានមកនៅឯខាងខ្ញុំនេះទេព្រោះកាលនឹងដីនឹងជាដីរបស់ខ្ញុំទេ។គាត់នឹងទៅនៅវិញពេលដែលផ្ទះនឹងត្រូវបានភ្លើងឆេះអស់ហើយ
កាលនឹងក្រោយមានសង្គ្រាមនឹងមានការទំលាក់គ្រប់បែកហើយដល់នឹងទៅគេបានទំលាក់ចំផ្ទះរបស់គាត់ហើយពេលនឹងគាត់អត់មានផ្ទះនៅទេនៅតែដីហើយផ្ទះកេរ្តិ៍ដំចឹងទៅពេលដែលវាឆេះអស់ហើយក៏បាននាំគ្នាទៅកសាងផ្ទះនៅលើដីនឹងបន្តទៀតចឹងទៅណា
ហើយក៏នៅដល់ខ្លួនតែត្រូវពេលដែលភ្លើងឆេះចឹងទៅក៏បាននៅផ្ទះខាងប្តីខ្ញុំនឹងទៅកាលពីដើមឡើយថាអោយកេរ្តិ៍នឹងមកប្តីខ្ញុំតែពេលដែលមានភ្លើងឆេះនឹងទៅក៏មានកូនចៅមកនៅឯផ្ទះនឹងទៅវិញបន្ទាប់ពីភ្លើងបានឆេះអស់ផ្ទះអស់ហើយនឹងដល់ពេលចឹងទៅគាត់ក៏បានមកសុំនៅផ្ទះខាងប្តីខ្ញុំវិញ
ពេលនឹងប្តីខ្ញុំនឹងក៏បានមកនៅឯដីខាងខ្ញុំវិញហើយក៏បាននាំគ្នាកសាងបានផ្ទះនៅនឹងទៅដោយមានការប្រក់ស្លឹក។
ពេលនឹងយើងក៏បានមកនៅជាមួយនឹងម្តាយចិញ្ចឹមខ្ញុំវិញទៅដែលជាអ្នកយកខ្ញុំមកចិញ្ចឹមនឹងថែរក្សាទៅ។

ក៖ ចឹងខាងលោកយាយវិញមានបងប្អូនប៉ុន្មាននាក់ដែល?

ខ៖
កាលនឹងខ្ញុំមានបងប្អូនតែម្នាក់ឯទេព្រោះកាលនឹងម្ដាយខ្ញុំបង្កើតនឹងគាត់មានកូនតែខ្ញុំទេហើយក៏ពេលដែលជីតានឹងគាត់អត់មានកូនពេលដែលរៀបការរួចចឹងហើយបានជាគាត់សុំខ្ញុំជាកូនអោយទៅនៅជាមួយ
ហើយម្ដាយខ្ញុំនឹងក៏បានអោយខ្ញុំនឹងទៅនៅជាមួយគាត់ទៅដែលជាឪពុកម្ដាយខ្ញុំបង្កើតនឹង។
ហើយក្រោយមកម្ដាយខ្ញុំនឹងប្ដីក៏ស្លាប់ទៅពេលដែលមានខ្ញុំនឹងហើយចឹងបានជាគាត់អោយខ្ញុំនឹងទៅនៅជាមួយនឹងជីដូនជីតាហើយគាត់បានយកប្ដីក្រោយទៀតចំណែកឯខ្ញុំនឹងបាននៅជាមួយនឹងជីដូនជីតានៅក្រោយនឹងទៅ
ហើយពួកគាត់បានទុកខ្ញុំនឹងដូចជាកូនគាត់ចឹងរហូតដល់ពេលដែលខ្ញុំនឹងបានពេញរូបពេញរាងទៅហើយគាត់ក៏បានរៀបការអោយខ្ញុំទៅហើយចឹងទៅខ្ញុំក៏បានរៀបការទៅកាលនឹងនោះ។

ក៖ ចាស! ហើយដ៏ពេលចឹងកាលនឹងលោកយាយមាននៅម្ដាយបង្កើតឈ្មោះអ្វីដែល?

ខ៖ ឪពុកដែលស្លាប់ទៅនឹងគាត់មានឈ្មោះថាតាងោសែល ។

ក៖ ហើយចុះម្ដាយលោកយាយវិញ?

ខ៖ ម្ដាយគាត់មានឈ្មោះថាយាយហួយ។

ក៖ ចាស!
ចឹងពេលដែលឪពុកលោកយាយបានស្លាប់ទៅលោកយាយហួយនឹងបានយកស្វាមីក្រោយទៀតហើយក៏មានកូនដែរ?

ខ៖ មានកូនដែរគាត់មានកូនក្រោយទៀតមាន៥នាក់។

ក៖ ចាស!ពួកគាត់មានឈ្មោះអ្វីខ្លះដែលទៅលោកយាយឈ្មោះរបស់គាត់?

ខ៖ អឺ
កាលនឹងគាត់បានយកប្ដីក្រោយទៀតនឹងគាត់បានមានកូន៥នាក់ហើយកូនក្រោយនឹងគេមាន

ឈ្មោះថា កុង ហើយទៅឈ្មោះ ហ្វ ហើយទៅទី៣មានឈ្មោះថា ហ៊ុច ហើយទី៤មានឈ្មោះថាអាន ហើយទី៥នឹងមានឈ្មោះថា តីនឹង។

ក៖
ចឹងលោកយាយមានបងប្អូនចំនួន៥នាក់នឹងលោកយាយចុះបងប្អូនលោកតាកុយវិញតើគាត់មានបងប្អូនប៉ុន្មាននាក់ដែល?

ខ៖
អត់ទេគាត់អត់មានទេព្រោះកាលនឹងឪពុកបង្កើតនឹងគាត់ដូចជាខ្ញុំនឹងមានតែមួយដែលហើយគាត់ក៏បានស្លាប់ដែលទៅ។

ក៖ ហើយចឹងឪពុកម្តាយបង្កើតរបស់លោកតាកុយនឹងមានឈ្មោះអ្វីដែរទៅ?

ខ៖ គាត់មានឈ្មោះថាតាមី ចំណែកឯខាងម្តាយវិញគាត់មានឈ្មោះថាយាយថៃ ហៅថាតាមីនឹងយាយថៃជាឪពុកម្តាយរបស់គាត់។

ក៖ ចាស!
ចុះពួកគាត់ទាំងពីរនាក់នឹងមានប្រវត្តិដូចលោកយាយយ៉ាងម៉េចខ្លះដែលទៅ?ដូចថាពួកគាត់មានស្លាប់ទៅហើយគាត់បានយកប្តីក្រោយដែលឬទេលោកយាយ?

ខ៖ ចំណែកឯឪពុកម្តាយបង្កើតរបស់ឈ្មោះកុយនឹងដល់ពេលដែលគាត់បានកើតមក គឺថាពេលដែលឈ្មោះកុយនឹងបានកើតមកនឹងបាន២ទៅ៣ទៅ៤ឆ្នាំនឹងម្តាយនឹងក៏បានស្លាប់ទៅហើយឪពុកនឹងក៏ទៅរកប្រពន្ធមួយទៀត
ហើយដណ្តឹងគេយកប្រពន្ធមួយទៀតទៅហើយទៅក៏ឈ្មោះកុយនឹងក៏បានទៅនៅជាមួយនឹងម្តាយចិញ្ចឹមនឹងដែលដូចគ្នាចឹងប្រវត្តិឈ្មោះកុយនឹងដូចគ្នាជាមួយនឹងឪពុកម្តាយចិញ្ចឹមនឹងដូចគ្នាគឺឪពុកម្តាយនឹងបានស្លាប់ទៅក៏សុទ្ធតែកំព្រាក៏បានឪពុកម្តាយចិញ្ចឹមនៅទៅសុំក្មួយៗនឹងយកទៅរៀបការទៅ ស្រាប់តែបានកើតមកជាចៅស្រាប់តែស្លាប់អស់។
ខាងខ្ញុំនឹងស្លាប់ឪពុកហើយខាងខ្ញុំនឹងស្លាប់ម្តាយ។

ក៖ ចាស!ពេលនឹងតើម្តាយគាត់មានឈ្មោះអ្វីដែលលោកយាយ?

ខ៖ ឈ្មោះថា ថៃនឹង។

កៈ
ចុះពេលដែលឪពុករបស់កុងបានរៀបការប្រពន្ធក្រោយនឹងមានឈ្មោះអ្វីដែលលោកយាយ?

ខៈ ហាយ ខ្ញុំមិនសូវដឹងដែលប្រវត្តិគាត់នឹង
ដល់ពេលដេលរួចទៅគាត់បានទៅនៅឆ្ងាយត្រូវជាឪពុករបស់ឈ្មោះកុយនឹងនោះពេលនឹងមិនដឹងថាគាត់ទៅនឹងយកប្រពន្ធឈ្មោះអីផងព្រោះកាលនឹងគាត់បានទៅឆ្ងាយ។

កៈ ចុះបន្ទាប់មកតើគាត់មានប្រពន្ធក្រោយនឹងមានកូនបានប៉ុន្មាននាក់ដែល?

ខៈ
កូនមានប៉ុន្តែអត់មានដឹងដែលព្រោះគាត់មានយកប្រពន្ធក្រោយនឹងគាត់មិនបានថាមានកូនប៉ុន្មានទេយាយអត់បានដឹងទេថាពេលដែលគាត់យកប្រពន្ធក្រោយនឹងមានឈ្មោះអីហើយកូននឹងមានប៉ុន្មាននាក់ទេចៅ។

កៈ ចឹងយាយអត់បានដឹងទេ?

ខៈ អត់ដឹងទេ។

កៈ ចុះយាយហេង?

ខៈ ហាស

កៈ
ចុះលោកយាយមិនបានដឹងទេថាឥឡូវបងប្អូនលោកតាកុយមានឬអត់ហើយតើពួកគាត់មានប៉ុន្មាននាក់ដែរ?

ខៈ
កាលនឹងបងប្អូនគាត់មានតែខ្លះទៅបានស្លាប់នៅក្នុងជំនាន់អាពតទៅហើយពេលឥឡូវនឹងនៅសល់តើមានបងប្អូនខាងម្ដាយ
ហើយបងប្អូននឹងខ្លះទៅគេគីនៅរស់ហើយខ្លះទៅគេក៏បានចាស់ទៅស្លាប់ទៅ។

កៈ ហឺ ចឹងលោកតាកុងគាត់អត់មានបងប្អូនបង្កើតទេលោកយាយ?

ខ៖ អត់មានទេគាត់ជាកូនទោល។ គាត់គេកូនទោលតែមួយនឹង។

ក៖ ចុះពេលដែលប៉ាលោកតាកុយយកប្រពន្ធក្រោយនឹងមានកូនទៀតដែរឬទេ?

ខ៖
មានតែគេទៅនៅរកស៊ីឆ្ងាយណាស់។ពេលនឹងគាត់បានទៅយកប្រពន្ធថ្មីនឹងនៅស្រុកឆ្ងាយនឹង យើងមិនបានដឹងហើយស្គាល់ប្រពន្ធគាត់ផងនឹងហើយទាំងកូនរបស់គាត់ទេយើងមិនបានទៅស្គាលទេចៅព្រោះចឹងហើយបានជាយើងដាច់ចេញពីគេទៅអត់មានស្គាល់នឹងដឹងពីគេទេ។

ក៖ ចុះយាយហេងនោះ?

ខ៖ ហាស អានឹងជីតាចិញ្ចឹមទេ។

ក៖
អូចឹងតើលោកយាយអាចរៀបរាប់បានទេថាលោកតាកុយនឹងគាត់មានបងប្អូនប៉ុន្មាននាក់ដែរ ដែលនៅជាមួយនឹងតាចិញ្ចឹមនឹង?

ខ៖ អឺ កាលនឹងគាត់ជាកូនទោលទេ
នៅជាមួយនឹងជីតានឹងជីដូននឹងពេលដល់ពេលដែលជីដូននឹងស្លាប់ទៅជីតានឹងក៏បានទៅយក ប្រពន្ធក្រោយទៀត
ពេលនឹងគាត់មានទៅណ្ដឹងគេហើយរៀបការប្រពន្ធក្រោយទៀតហើយក៏បានកូន ៤ក្រោយនេះ ប៉ុន្តែចំណែកឯតាកុយនឹងគាត់ជាកូនទោលទេ។

ក៖
ហើយលោកតាដែលចិញ្ចឹមលោកតាកុងនឹងគាត់យកប្រពន្ធមួយទៀតហើយនឹងគាត់ក៏បានយកប្រពន្ធមួយទៀតនឹង
ហើយគាត់មានកូនចំនួន៤នាក់?តើពួកគាត់មានឈ្មោះអ្វីខ្លះទៅលោកយាយ?

ខ៖ នឹងហើយពេលដែលយកប្រពន្ធកូននឹងគាត់មានកូនចំនួន៤នាក់។គាត់មានឈ្មោះ កាក់ គឹមសន កាក់គឹម សេង កាក់គឹម ផល្លី នឹង កាក់ គឹមហេង។ គាត់មានកូនសុទ្ធតែស្រីអូចាស។

ក៖ អូ!!! ចឹងហើយតើសព្វថ្ងៃនឹងពួកគាត់មានទីលំនៅទៅឯណាខ្លះទៅលោកយាយ?

ខ៖
ឥឡូវនឹងកូនបងៗគេចេញពីទីលំនៅចាស់នឹងទៅនៅកន្លែងផ្សេងៗគ្នាអស់ទៅរកស៊ីអស់ហើយនៅផ្ទះចាស់នឹងមានតែកូនពៅនៅនឹង គេទៅនៅឆ្ងាយទៅវាមិនបាននៅជុំគ្នាឯណា។

ក៖ ហឺស ចាសចឹងលោកយាយ
ដល់ពេលបន្ទាប់មកលោកយាយបានរៀបការមកនៅជាមួយនឹងលោកតាហើយលោកយាយនឹងលោកតាក៏បានបង្កើតគ្រួសារមួយដែលដល់ពេលហើយទៅតើលោកតានឹងលោកយាយដែលមានជួយចិញ្ចឹមលោកយាយនឹងលោកតាកុយនឹងតើពួកគាត់នៅមានអាយុជីវិតនៅឡើយក៏ពួកគាត់ស្លាប់បាត់ទៅហើយ?

ខ៖ ពួកគាត់បានស្លាប់អស់ទៅអស់ហើយកាលពីជំនាន់នោះឯន៎។

ក៖
ចាស!ចុះលោកតាកុយដែលត្រូវជាប្ដីលោកយាយវិញតើគាត់បានស្លាប់នៅក្នុងឆ្នាំណាដែលលោកយាយ?

ក៖
កាលនឹងពេលដែលយាយបានរៀបការហើយគាត់ក៏បានស្លាប់នៅក្នុងជំនាន់អុងតាក់ឯនេះទេប៉ុន្តែខ្ញុំមិនបានចាំទេព្រោះថាពេលនឹងគាត់បានស្លាប់ក្នុងពេលដែលនឹងកំពុងតែបោះឆ្នោតនៅក្នុងសម័យអ៊ុន តាក់នឹង
ដូចជានៅក្នុងឆ្នាំ១៩៩១មិនដឹង១៩៩២មិនដឹងយាយចាំមិនបានច្បាស់ទេកាលនឹងនោះ
ហើយគាត់បានស្លាប់ទៅយាយនឹងបានចិញ្ចឹមកូន៨នាក់នឹងហើយពេលនឹងយាយបានធ្វើនំលក់នៅផ្ទះនឹងហើយយកទៅលក់នៅផ្សារនៅខាងមុខផ្ទះនឹងថៅកាលនឹងយាយនឹងតាកុយនឹងបានរើសមកផ្លាស់លំនៅនៅពាមក្នុងហើយថៅអើយអត់មាននៅឯព្រែកក្របៅទៀតទេថៅអើយ។
បន្ទាប់មកពេលដែលមានកូនៗនឹងគេរាងធំៗទៅយាយនឹងបានលើកអោយគេខ្លះទៅហើយគេក៏បានទៅរស់នៅបែកគ្នាខ្លះទៅហើយយាយបានមានមុខរបរធ្វើនំនឹងតាំងពីពេលមុននឹងរហូតដល់ពេលឥឡូវនឹងយាយនៅធ្វើវាខ្លះចឹងទៅដើម្បីបានលុយបន្តិចបន្តួចសំរាប់ទុកដាក់នៅពេលយាយនឹងចាស់ទៅហើយផ្សំវានឹងទុកធ្វើបុណ្យទានណាថៅ។

កៈ តើលោកតាស្លាប់ដោយសារអ្វីដែលលោកយាយ?

ខៈ កាលនឹងជំងឺលើសឈាមនឹងពេទ្រមើលមិនជាទេឬលោកយាយ?

កៈ
កាលនឹងទៅដល់ពេទ្រនៅកាលម៉ែតដែលប៉ុន្តែកាលលនឹងកុយនឹងគាត់ឈឺធ្ងន់ហើយមិនបានមួយអាទិត្យ
ផងពេលដែលដឹកមកពីពេទ្រវិញនឹងមិនបាននឹងមួយអាទិញផងគាត់ក៏បានស្លាប់បាត់ទៅ និយាយទៅពេលនឹងពេទ្យគេថាជំងឺកុយនឹងគាត់ឈឺធ្ងន់ហើយពេលនឹងគាត់ហើមខ្លាំងហើយបានយកទៅពេទ្រនោះចឹងពេទ្រគេថាមិនអាចនឹងព្យាបាលបានទេចឹងគេអោយដឹកមកផ្ទះវិញហើយពេលដែលដឹកមកផ្ទះវិញនឹងកុយនឹងគាត់រស់នៅដង្ហើមនឹងបានប្រហែល៣ថ្ងៃដែលហើយយាយនឹងក៏ធ្វើបុណ្យអោយគាត់ទៅតែពេលដេលគាត់នៅមិនទាន់ដាច់ដង្ហើមនឹងគឺយាយបានហៅគេអោយមកផ្ទះដើម្បីនឹងសូត្រមុនអោយគាត់នៅផ្ទះដោយមាននិមិត្តលោកសង្ឃនឹងតាអាចាជាដើមមកដើមធ្វើពីធីសូត្រមុនអោយគាត់បានពេលគាត់នៅដង្ហើម។

កៈ កាលនឹងកុងកុយគាត់កើតអីដែលយាយបានគាត់ស្លាប់?

ខៈ
កាលនឹងកុយឯងនឹងគាត់មានជំងឺលើសឈាមធ្ងន់ធ្ងរហើយនឹងបានពេទ្យគេមើលអោយហើយគេបានប្រាប់យើងដែលថាជំងឺនេះ
គេប្រាប់ថាដូចជាគេប្រៀបធៀបនឹងត្រណុបទេណាស់ពេលដែលគេដាក់ត្រណុបអីទៅវាគ្រាន់ទេទុបទេណា ទើបថាអោយវានឹងថយវាមិនចឹងទេ
វាបានតែទប់ៗទេគេធៀបដូចជាទំណុបចឹងអាជំងឺលើសឈាមនឹងនោះហើយក៏យកមកវិញកាលនឹងមួយលងមក១យប់ទៅ២យប់ក៏គាត់ខូតទៅ
ហើយកាលនឹងគាត់ខូតនឹងនៅពេលដែលចំពេលគេអុំទូកកាកលនឹងនោះចំពេលទិវេអុំទូកតែម្តង។

កៈ
អូកាលនឹងសោកស្តាយមែនទែនលោកយាយហើយកាលនឹងតើលោកតាគាត់កាលនឹងមានបានប្រកបមុខរបរអ្វីដេលលោកយាយកាលនឹងនោះ?

ខ៖
កាលនឹងគាត់មិនបានទាន់រកអីទេកាលនឹងនោះគាត់បានតែទៅធ្វើធ្នូសដាក់ត្រីយកមកទៅ។

ក៖ ចាស!កាលនឹងគាត់ជាអ្នកចូលហ៊ុនសំរាប់ដាក់ធ្នូស?

ខ៖ ចឹងហើយថៅតាឯងនឹងហើយគាត់បានធ្វើធ្នូសនឹងសំរាប់ដាក់ត្រីគ្រាន់បានមកដែរ។

ក៖
ចឹងលោកយាយនឹងលោតានឹងពេលនឹងតើយាយនឹងលោកតានឹងបានចូលរៀនដែលឬទេ?

ខ៖
បានកាលនឹងនោះបានចូលរៀនតែមិនបានចេះអក្សរច្រើនអីទេតែបានកត់បញ្ជី១រយអីចេះព្រោះកាលពីដើមនឹងគេគ្មានកាសសូលចឹងទេឬម៉ាស៊ីនគិតលេខចឹងទេគេគិតតាមតែក្បត់គេគិតលេខនឹងទេបើត្រូវបូកដកអីនឹងគេចេះដឹងតាមរបៀបគេ
ដូចក្បិចចិនចឹងកាលនឹងគេហៅថាក្បត់ចិនចឹងដែរកាលពីដើមតែជារបស់ខ្មែរយើងគេហៅក្បាត់ស្រីនឹងរបៀបផ្សេងៗទៀតទៅតាមប្រភេទរបស់មនុស្ស។ហើយកាលនឹងគេប្រើឧបករណ៍វាពងដូចជាអង្កាំមានគ្រាប់នៅលើនោះ។
គេបានបូកក្បាច់នឹងអោយសំរាប់គិតលេខកាលជំនាន់នឹងនោះថៅអី។

ក៖ ចាស!
ហើយចុះកាលសិក្សានៅជំនាន់នឹងគេរៀនបានថ្នាក់ទីប៉ុន្មានដែលលោកយាយតើការនឹងគេគិតយ៉ាងម៉េចដែលគេមានថ្នាក់ទីប៉ុន្មានខ្លះទៅ?

ខ៖
កាលជំនាន់នឹងយាយដឹងថាគេមានរៀនបានត្រឹមថ្នាក់ទី៧កាលនឹងនោះហើយបើតាមខ្ញុំដឹងកាលនឹងរៀនបានទី៧ហើយគេបានអោយបានទៅរៀនចូលថ្នាក់ការលេសហើយកាលនឹងមានន័យថាកាលនឹងគេអោយយើងនឹងរៀនបានត្រឹមថ្នាក់ទី៧ហើយគេអោយយើងនឹងអាចបន្តការសិក្សានៅថ្នាក់កាលេសបាន។

ក៖ ចឹងតើលោកយាយរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ហឺ!!!កាលនឹងយាយបានរៀនត្រឹមថ្នាក់ទី៤និងទី៣ក៏ឈប់ទៅ
បានគ្រាន់តែចេះអីកាលនៅជំនាន់នឹងក៏បានឈប់ទៅ។

ក៖
ហើយកាលនឹងលោកយាយបានរៀននៅសាលាណាដែលតើលោកយាយបានចាំដែលឬទេ?

ខ៖
កាលនឹងយាយបានទៅរៀននៅសាលាពាមក្នុងដែលពីមុនឡើយនឹងយាយរៀននៅវត្តលោកទេចៅតែដល់ពេលក្រោយមកនឹងយាយបានចូលរៀននៅសាលាពាមក្នុងនឹងបានត្រឹមថ្នាក់ទី៧ហើយអ្នកណាដែលរៀនចប់ត្រឹមថ្នាក់ទី៧នឹងបានគេអោយយើងនឹងឡើងថ្នាក់ចូលរៀននៅថ្នាក់កាលេសនៅឯសាលាឯពាមជីកងឯនោះកាលនឹងសាលាកាលេសនឹងនៅពាមជីកង។

ក៖ ចាស!ហើយចុះលោកតាវិញ?

ខ៖ និយាយរឿងលោកតានឹងហាហ៎ា

ក៖ ចុះរឿងរបស់លោកយាយវិញតើមានបានរៀនដូចទៅនឹងលោកតាដែលឬទេបើអីចឹងនោះ?

ខ៖ អើយ!!!
លោកតានឹងគាត់បានរៀនបានច្រើនជាងខ្ញុំកាលនឹងនោះប៉ុន្តែខ្ញុំវិញកាលនឹងគឺរៀនបានត្រឹមតែថ្នាក់ទី៣ទេកាលនឹងយាយនឹងរៀនបានត្រឹមនឹងអីនឹងចៅ។

ក៖
ចុះកាលនឹងយាយបានដឹងទេថាលោកតាបានរៀនដល់កំរិះណាដែលតើគាត់មានបានប្រាប់លោកយាយដែលឬទេ?

ខ៖ ទេអត់មានបានប្រាប់នឹងយាយអោយបានដឹងទេកាលនឹងនោះ
ប្រាប់ទេកាលនឹងប៉ុន្តែកាលនឹងយាយដូចជាបាដឹងថាគាត់ដូចជាបានចូលរៀននៅឯថ្នាក់កាលេសចឹងដែលដូចជាចឹងមិនដឹងកាលនេងនោះ។

កៈ
ចាសៗអឺចឹងកាលនឹងលោកតានិងលោកយាយឪពុកម្តាយជាអ្នកដែលរៀបចំអោយកាលនឹងមិនមែនបានស្រលាញ់គ្នាមុននោះទេ?

ខៈ អើកាលនឹងចឹងហើយ កាលនឹងយាយនឹងតាឯងនឹងមិនបានស្រលាញ់គ្នាមុនទេ គឺសុទ្ធតែឪពុកគាត់ជាអ្នកដែលរៀបចំអោយទេកាលនឹងនោះ អើហើយកាលនឹងគាត់បានរៀបអោយចូលតាមច្បាប់នឹង។

កៈ ហើយចឹងកាលនឹងលោកយាយនឹងលោកតាបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់កាលនឹង?

ខៈ
អើកាលនឹងយាយនឹងបានរៀបតាមច្បាប់តែមិនបានស្រលាញ់គ្នាមុនអីណាទេកាលនឹងនោះទេ ឪពុកម្តាយគាត់ជាអ្នកទុកដាក់អោយយាយទេកាលនឹងនោះ។

កៈ
ចាស!ចឹងកាលនឹងលោកតាបានការជាមួយនឹងលោកតាបានកាលនឹងនៅក្នុងជំនាន់ណាដែលលោកយាយ?

ខៈ
កាលនឹងមិនបានដឹងទេវាបានភ្លេចផ្លាំងអស់ទៅហើយថានៅក្នុងជំនាន់ណាទេកាលនឹងនោះវាយូរហើយចៅ។

កៈ
ហើយចឹងកាលនឹងយាយបានការជាមួយនឹងលោកតានៅក្នុងសម័យពពតឬក៏ក្រោយសម័យពពតលោកយាយ?

ខៈ ហ្វស!! មុនឯណោះ

កៈ មុនសម័យអាពតទៀតលោកយាយណោះ?

ខៈ
ហើកាលនឹងបានជាមុននឹងព្រោះកាលនឹងយាយនឹងបានដឹងថាកាលនឹងគេមានទំលាក់គ្រាប់

បែកមកកូនបង ពរត់ចូលទៅក្នុងព្រៃចូលទៅក្នុងកាត្រង់សុកនេស កាលនឹងហ៎កាលនឹងជំនាន់លុនណល់គេបានទំលាក់មកណាកាលជំនាន់លុនណល់មកគេបានមកទំលាក់គ្រប់បែកមក កាលនឹងគេហៅថាកៅគី កៅអីនឹង ពេលនឹងយាយបានមានកូនចំនួនមួយនឹងបានតែមួយនឹងកាលនឹងហើយពេលនឹងយាយបានរត់ចូលច្រក់នឹងរន្ធដៅការត្រសុកនឹងគេជាកូនព្រោះកាលនឹងគេបានទំលាក់គ្រប់បែកមកឡើងរញ៉ដីអស់ហើយ យាយនឹងពរកូនឹងរត់ចូលហើយក៏ចេញមកពីទៅរត់ចូលព្រៃកាត់អីទៅល្មមបានវាផុតពីជំនាន់នឹងហើយគេបានឈប់ទំលាក់មកនោះវាភ័យណាស់កាលនឹងនោះប៉ុន្តែមិនបានដឹងត្រូវធ្វើយ៉ាងម៉េចទេដល់ចឹងទៅបានជាយាយនឹងនឹកថាបន់អោយតែវានឹងឈប់ទំលាក់ឆាប់ៗទេកាលនឹងនោះព្រោះយាយនឹងនៅភ័យខ្លាចហើយញ៉ាំបាយវាមិនចង់ត្រង់ទេអោយតែលឺសំលេងវាដូចជាយន្តហោះនឹងយាយរត់ទៅពួងហើយបានចេះអីវាបានឈប់ទំលាក់នឹងមកនោះរាងធូបន្តិច។

ក៖ ដល់ពេលហើយកាលនៅកំណើតរបស់កូនបងរបស់លោកយាយដែលចឹងកាលនឹងតើគាត់មានអាយុប៉ុន្មានឆ្នាំដែល?ចាសចឹងកាលនឹងយាយបានដឹងដែលឬទេថាកាលនឹងសម័យលុនណុលនឹងបានផុតទៅតើកូនរបស់លោកយាយនឹងមានអាយុ ប៉ុន្មានឆ្នាំដែលបានចូលមក្នុងជំនាន់អាពត?

ខ៖ កាលនឹងវានៅធំដែលហើយ ពេលដែលបានឆ្លងកាត់របបលុនណុលនឹងរហូតដល់បានដាច់អាពតមកនោះវាមើលទៅបានរាងធំដែលគួសមនឹងដែលនឹងកាលនោះហ៎។

ក៖ ចាស!ចឹងកាលនឹងតើលោកយាយមានកូនបន្ទាប់មកទៀតមានអាយុប៉ុន្មានដែល?

ខ៖ ចាស!កាលនឹងខ្ញុំមានកូនទៀតហើយមានដូចជាកូនឈ្មោះកុយសុភាពនឹង កូនឈ្មោះកុយសុភី ហើយកូនឈ្មោះកុយ សុភ័ណ្ឌ កូនឈ្មោះកុយ សុកល នឹងកូនចុងក្រោយឈ្មោះកុយ ចេកនឹងមួយទៀតកាលនឹងនៅសម័យពពតនឹងយាយបានកូនទាំងអស់បានចំនួន៥នាក់នឹងដែលកាលនឹងនោះ។

កៈ ចាស!ចឹងលោកយាយបានកូន៥នាក់កាលនៅសម័យពពត?

ខៈ
ចាស!កាលនឹងយាយបានកូន៥នាក់ស្រីបាន៣នាក់ហើយប្រុសបាន២នាក់ដែលកាលនឹងនោះហើយពេលបានដាច់ជំនាន់អាពតហើយយាយនឹងបានកូនចំនួន៣នាក់ទៀតកាលនឹងហើយយាយណាបានចិញ្ចឹមកូនទាំងអស់នឹងហើយកូន៣នាក់ក្រោយជំនាន់អាពតនឹងមានបានស្រី១នាក់ហើយកូនប្រុសនឹងបន្ទាប់គឺបាន២នាក់សរុបគឺបាន៣នាក់។

កៈ ចាស!ចឹងយាយបានមានកូនដែលរួចផុតពីជំនាន់អាពតមកគឺមានចំនួន៣នាក់ទៀតដែរហើយចឹងនៅក្នុងសម័យពពតនឹងពេលដែលចឹងកាលនឹងតើគេបានជំលៀសលោកយាយទៅណាដែល?

ខៈ កាលនឹងយាយបានចូលនៅក្នុងសម័យពពតនឹងហ៎?

កៈ ចាស!!!

ខៈ
កាលនឹងយាយបាននៅក្នុងកន្លែងកំណើតរបស់ខ្លួនឯទេយាយមិនបានគេត្រូវអោយផ្លាស់ទីលំនៅឬត្រូវបានគេជំលៀសទៅនៅឯស្រុកក្រៅឡើយចៅអើយកាលនឹងយាយនៅក្នុងផ្ទាល់ខ្លួនឯងតែម្តង
ព្រោះអីកាលនឹងគេបានថាយើងនឹងជាប្រជាជនចាស់ដ៏ចឹងហើយគេអោយយើងនៅស្រុកយើងហើយធ្វើស្រែអីនៅនឹងម៉ង់
គេមិនជំលៀសចេញទេព្រោះគេដឹងថាយើងនឹងធ្វើការកម្មក្រាស់នៅក្នុងស្រុកនឹងផ្ទាល់តែម្តងបើគេជំលៀសនោះគេជំលៀសតែពួកប្រជាជនដែលគេជំលៀសពីភ្នំពេញមកទេដល់ពេលចឹងទៅបានជាគេអោយយើងនៅហើយប្រជាជនថ្មីនឹងត្រូវបានគេជំលៀសទៅណាទៅនៃអីចឹងទៅ។

កៈ អូ!!!

ខៈ ចឹងហើយបានថាយើងជាប្រជាជនចាស់ចឹងគេអោយយើងនៅកន្លែងតែម្តង។

កៈ
ចាស!ចឹងកាលនឹងក្រុមគ្រួសាររបស់លោកយាយបាននៅជាមួយនឹងគ្នាដែលឬទេកាលនឹង
នោះ?

ខៈ
នឹងហើយកាលនឹងយាយបាននៅជាមួយនឹងក្រុមគ្រួសារយាយដល់តែពេលបានដាច់អាពត
ហើយនឹងយាយបាននៅជាមួយនឹងគ្នាមិនមានកូនចៅណាបែកគ្នាទេកាលនឹងនោះប៉ុន្តែកាល
នឹងយាយនឹងវាវេទនាណាកាលនឹងនោះវាទំរាំមបានកាច់មកនឹងនោះចៅអើយ
អានឹងបានវាថាបានជាទឹកដោះម៉ែវាថ្លៃ គេសុទ្ធតែបានដាក់ងារអោយយើងថាពួកមារធន
គឺជាពួកដែលជិះជាន់គេព្រោះកាលនឹងយើងមានកម្មករអីចឹងហើយពេលនឹងយាយបានប្រើគេ
អីសំរាប់ជួយការងារហើយអោយលុយគេនឹងប៉ុន្តែគេហៅយើងថាជាអ្នកមូលធនកាលនឹងនោះ
នឹងហើយ អានឹងពួកសុទ្ធដែលមូលធនហើយ
ប៉ុន្តែពួកអ្នកដើរស៊ីឈ្នួលគេអីនឹងឬអ្នកក្រនឹងគេហៅថាពួកនេសស្ទីគេទេយាយបានភ្លេចបាត់
ទៅហើយកាលនឹងនោះយាយដឹងត្រឹមថាគេនឹងបានហៅថាពួកនឹងគេអ្នកដែល
ល្អហើយគេបានលើកដំកើន
ហើយពេលនឹងនោះគេថាយើងនឹងអ្នកមានអ្នកដែលគេដាក់ងារអោយជាអ្នកមូលធននឹងនោះ
ប៉ុន្តែវាមិនចឹងអីកាលនឹងយាយនឹងតានឹងគ្រាន់តែរកស៊ីបានតិចតួចហើយជួលគេអោយជួយធ្វើ
នឹងហើយរកបានមកបានមធ្យមនឹង
តែគេថាយើងនឹងមូលធនព្រោះតែមានកម្មករអីនឹងហើយគេបានឃើញយើងនឹងវាមានយើងនឹ
ងមានដាំឈូកហើយសល់លុយចឹងគេក៏ហៅយើងថាពួកមូលធនទៅចៅអើយ
ហើយពេលនឹងយើងធ្វើនឹងគេថាយើងជាពួកមូលធនជាអ្នកដែលជិះជាន់គេព្រោះគេឃើញយើ
ងនឹងវាមានជួលកម្មករហើយជាអ្នកដែលជិះជាន់កំលាំងពលកម្មគេ
តែតាមពិតទៅយើងគ្រាន់តែធ្វើវាមិនអស់ព្រោះច្រើនពេកចឹងទៅយើងគ្រាន់តែជួលគេដែលគ្មា
នការងារធ្វើនឹងអោយមកជួយហើយយើងអោយលុយសោះនឹងក៏ថាយើងនឹងវាជាអ្នកជិះជាន់
គេដែលពួកនឹងនោះ។ ចំណែកឯអ្នកដែលធ្លាប់យើងជួលនឹងហើយអ្នកក្រៗ
អ្នកដែលរកស៊ីនឹងគឺគេបានដំឡើងអោយធ្វើការងារធំៗហើយគេលើកតំកើនធ្វើជាមេគេវិញកា
លនឹងនោះ ហើយការនឹងគេអោយពួកនឹងកាន់ឃ្លាំង
កាន់ស្ទីៗនឹងព្រោះគេគិតឃើញថាអ្នកទាំងអស់នឹងប្រវត្តិវាល្អ។

កៈ អើ!!!

ខៈ
ហើយបើយើងមានស៊ីអីដូចចឹងៗអីនឹងគេថាយើងនឹងជាអ្នកមូលធនជាអ្នកដែលជិះជាន់គេវិញ
ជាអ្នកដែលបានជិះជាន់កំលាំងពលកម្មគេវិញ។

កៈ អើ!ចឹងគេអោយយាយធ្វើអ្វីខ្លះទៅ?

ខៈ គេចាត់ទៅគេអោយយើងទៅបាច់ទឹកទៅ គេអោយយើងនឹងទៅស្ទូងស្រូវអីចឹងទៅ
ហើយបើថាយើងនឹងមានកូនចឹងគេអោយយើងនឹងទៅជាមេដោះទៅ
គេយើងចាស់ណាដែលគេត្រូវបានរើសជាមេដោះនឹង
ពេលដែលដល់ប្រលឹមឡើងនឹងដែលត្រូវទៅធ្វើការនឹងគេបានយកកូនមកដាក់អោយគេមើល
ចឹងទៅហើយដល់ពេលដែលរាងល្ងាចចឹងទៅបានមកយកកូនទៅផ្ទះវិញចឹងទៅហើយគេនឹង
បានយកកូនគេរាងៗខ្លួនគេទៅវិញទៅផ្ទះគេនឹងរាងៗខ្លួនគេទៅ។
អានឹងគេហៅកន្លែងនឹងថាជាកន្លែងមេដោះសំរាប់អោយគេយកកូនៗគេមកភ្ញើរហើយគេនឹង
ទៅធ្វើការហើយពេលដែលចប់ធ្វើការហើយគេយកទទួលយកកូនគេវិញទៅ។
ហើយនិយាយពីយាយកាលនឹងណាមានកូន១ដែលគឺជាកំណើតរបស់កូនឈ្មោះ កល
អាកលនឹង
យាយបានធ្វើមេដោះអោយគេចឹងដែលទៅព្រោះកាលនឹងយើងនៅកូនវាខ្ចីចឹងគេអោយយើង
នឹងមើលកូនអោយគេហើយដល់ពេលដែលយើងអោយកូននឹងទៅគេចឹងទៅបានជាគេអោយ
យើងនឹងទៅមើលកូនអោយគេចឹងទៅហើយពេលដែលកូនគេនឹងវាឃ្លានម៉ុងអីចឹងទៅយាយនឹ
ងក៏អោយវានឹងម៉ុងអីចឹងដែលជាមួយនឹងកូនយើងនឹងទៅកាលនឹងនោះហើយនិយាយថាកា
លនឹងយាយនឹងណា
គេអោយមើលកូនគេអស់នៅមួយភូមិនឹងគេយកមកភ្ញើរយើងពេលដែលល្ងាចគេយកទៅផ្ទះ
គេវិញហើយពេលដែលព្រលឹមនឹងគេយកកូនគេមកដាក់អោយយើងមើលថៃចឹងទៅ
ហើយយើងនឹងនៅចាំមើលចឹងទៅ
ហើយពេលដែលដល់ព្រលឹមនឹងយើងត្រូវទៅកន្លែងនឹងទៅហើយពេលដែលល្ងាចឡើងនឹង
យើងទៅផ្ទះយើងដែលទៅគេហៅដូចថាផ្ទះមួយនឹងរាងមានកន្លែងទូលាយចឹងទៅយើងគេអោ
យយើង២ទៅ៣នាក់ចឹងយើងមានកូននៅខ្ចីៗចឹងមិនទាន់បានបញ្ចេញកំលាំងពលកម្មបានចឹង

ហើយគេអោយយើងនឹងមើលកូនអោយគេចឹងទៅ ហើយអោយយើងមើលកូនគេ ដែលកូនគេនឹងយំ ហើយឃ្លានបៅឃ្លានអីចឹងទៅ ហើយមើលទាំងកូនគេរាងធំហើយនឹងក៏មើលដែលពេលដែលកូនគេនឹងត្រូវឃ្លានបាយអីនឹង យើងនឹងក៏ត្រូវតែបញ្ចុកបាយអោយអីចឹងទៅណាស់។

ក៖ អូ!!!ចឹងកាលនឹងយាយគឺជាមេដោះ?

ខ៖ អើ!កាលនឹងយាយគឺជាមេដោះហើយកាលនឹងជំនាន់កំណើតកូនកលនេះឯងព្រោះពេលនឹង យាយនូវកូនខ្ចីចឹងហើយគេមិនទាន់អោយយាយនឹងចេញទៅធ្វើការទេ ទើបទាល់តែយើងបានកូននឹងអាយុបាន៣ខែហើយបានជាគេនឹងអោយយើងទៅធ្វើការដូចជា គេដូចជាឯងចឹងទៅដល់កូនយើងវិញធំបាន៣ខែវិញយើងត្រូវចេញទៅហើយទុកកូនយើងនឹង អោយគេមើលវិញម្តង អានឹងវាចឹងទៅណា។

ក៖ ចាស!កាលនឹងគេអោយដូរគ្នា។

ខ៖ អើ!!កាលនឹងគេអោយយើងនឹងដូរគ្នាម្តងម្នាក់។

ក៖ ហើយកាលនឹងយាយបានមើលកូនគេនឹងប្រហែលជិត១០អីដែរយាយ?

ខ៖ អាប្រហែល១ភូមិនឹងបានដេលនឹងហាប្រហែល១០ទៅ១០អ្នកជាងអីចឹងទៅណាហើយពេល ខ្លះចឹងទៅវាមានលាយលំគ្នាចឹងទៅណាវាមាន១០ទៅតូចៗហើយខ្លះទៅវាមានធំៗដែលវាលា យគ្នាទៅមិនមែន១០ជាងនឹងសុទ្ធតែស្មើរៗគ្នានោះទេ។

ក៖ ហើយចឹងពេលហើយទៅគេអោយាយធ្វើអ្វីទៀត?

ខ៖ អើ!!ដល់ពេលហើយទៅពេលដែលយើងបានចាស់ខែទៅប្រហែលជា៣ខែអីចឹងទៅគេអោយ យើងនឹងឈប់ទៅគេអ្នកមានកូនក្រោយនឹងគេចូលមកមើលវិញម្តងហើយគេអោយយើងនឹង ទៅធ្វើការវិញម្តងហើយយើងក៏បានទុកកូនយើងទុកអោយគេមើលវិញម្តងទៅហើយជូនកាល ទៅយើងបានទៅធ្វើការដូចជាទៅបាច់ទឹកស្រែនៅជិតៗនឹងទៅ។

កៈ ចាស!កាលនឹងយាយបានបាច់ទឹកស្រែកនឹងប៉ុន្មានម៉ោងដែរទៅ?

ខៈ
កាលនឹងយាយបានទៅបាច់ទឹកស្រែពីព្រលឹមឡើងទៅហើយដល់ពេលថ្ងៃឡើងទៅយើងមកញ៉ាំបាយ
ស៊ីបាយហើយៗទៅយើងក៏ត្រូវទៅវិញរហូតដល់តែពេលល្ងាចចឹងទៅបានយើងមកផ្ទះយើងវិញចឹងទៅ។ គេអោយមកវិញនឹងប្រហែលជាម៉ោង៤អីនឹងហើយស៊ីទៅ
ហើយយកកូនមកវិញរាងខ្លួនចឹងទៅ ។

កៈ កាលនឹងយាយមានម៉ោងមើលដែលឬទេ?

ខៈ
កាលនឹងវាគ្មានម៉ោងពីណាមកមើលទេយាយមើលតែថ្ងៃថាពេលដែលថ្ងៃនឹងឡើងរាងជ្រៀល
ហើយយើងមកផ្ទះយើងវិញមក។

កៈ កាលនឹងយាយបានមកផ្ទះដោយខ្លួនឯងឬគេជាអ្នកប្រាប់យើង?

ខៈ កាលនឹងយើងមកខ្លួនឯគ្មាននរណាគេដើរហៅយើងទេ
ព្រោះកាលនឹងយើងដឹងថាពេលមើលទៅរាងល្ងាចហើយយើងត្រូវដឹងខ្លួនឯងនឹងហើយដើរមកផ្ទះយើងវិញមក។កាលនឹងយើងបានដឹងថាអោយតែថ្ងៃត្រង់នឹងតែម៉ោង១២ហើយចឹងហើយយើងមើលតាមថ្ងៃចឹងទៅហើយមកៗ ហើយមកស៊ីបាយមក។

កៈ ចឹងកាលនឹងគេអត់មានដើរហៅយើងឬទៅកងយើងទេ?

ខៈ
អត់ទេកាលនឹងមានដែលក៏មិនដឹងយាយដូចជាបានភ្លេចទៅខ្លះហើយកាលនឹងមានដូចជាជួងគេគោះដែលពេលដែលមុនដំបូងនឹងប៉ុន្តែយាយនឹងដូចជារាងស្រពិស្រពិលក្នុងចិត្តនឹងព្រោះវាយូរណាស់ដែលហើយយាយភ្លេចទៅ។

កៈ ហឺ!!!

ខ៖
ចឹង!ហើយយើងក៏ឡើងមកផ្ទះយើងវិញមកពេលដែលគេបានគោះជួងនឹងពេលមុនដំបូងនឹង
នោះកាលនឹង។

ក៖ ចាស!ហើយកាលនឹងគេបានអោយយាយបាយប៉ុន្មានពេលដែល?
អូកាលនឹងយាយបានបាយឬបបរកាលនឹង?

ខ៖
កាលនឹងបានបាយណារកឆ្អែកឯណាបើកាលនឹងគេដាំ១ខ្ទះនឹងបានអង្ក១កំប៉ុងអីជឹងបានបា
យឯណាស៊ីមិនទៅឆ្អែកអី ១ខ្ទះត្នោតបានអង្កតែ៨កំប៉ុងអីនឹង…

ក៖ ហើយចឹងមានគ្នាញុំានឹងប៉ុន្មាននាក់ដែល?

ខ៖ អើគ្នាបានប៉ុន្មាន ពេលដែលយើងទៅដល់វា..

ក៖ ក្នុង១ភូមិនឹងទៅ?

ខ៖
អើ!!ដូចយើងបានដូចស៊ីបបរនឹងបាន១វែកហើយរាវខ្លាំងណាស់គ្មានឃើញគ្រប់បាយមិចផងវា
រាវពេកហើយស៊ីមិនបានឆ្អែកអីកាលនឹងហើយដល់ទៅមែនទែនកាលនឹងស៊ីអត់គ្រប់គ្រាន់ចឹង
វាអស់កំលាំងមែនទែនហើយស៊ីមិនគ្រាប់គ្រាន់ចឹងទៅជាឈឺអស់ហើយឡើងហើមជើងអីកាល
នឹងហ់ា ហើយកាលនឹងអោយថាបានស៊ីខ្ជិតខ្ជីអីនឹងក៏ថាស៊ីទៅឆ្ងាញ់ដែល
ហើយពេលខ្លះមានគេនឹងស៊ីគល់ល្ហុងអីនឹងក៏ស៊ីដែរព្រោះវាឃ្លានពេកចុះបើកាលនឹងវាអោយ
យើងស៊ីមិនគ្រាប់គ្រាន់ចឹងហើយយើងមានតែស៊ីអីផ្សេងចឹងទៅ។

ក៖ អូ!!!ចឹងយាយកាលនឹងគេអោយយើងស៊ីអីចឹងដែល?

ខ៖
អត់ទេតែកាលនឹងយើងលួចស៊ីរួចទៅចេកដែលយើងបានដាំនឹងក្បែរៗផ្ទះអីមិនបានទេតិចថា
យើងទៅកាប់យកមកស៊ីអីអត់បានទេនេះពួកគាត់ដែលក្តោមក្តាបឃ្លាំងអីនឹងមេគេនឹងគេមិន
អោយយើងទេគេដើរកាប់ទៅដាក់នៅក្នុងឃ្លាំងអស់ហើយកាលនឹងនោះ។

ក៖ ហឺ!!!

ខ៖
ហើយកាលនឹងគេយកទៅទុកអស់ហើយដល់ពេលដែលវាទុំនឹងបានជាគេយកវាមកធ្វើបបរស្ករអោយយើងស៊ី១ដងនៅក្នុង១ខែហើយកាលនឹងវាមិនបានបបរចេកនឹងដាក់ស្ករអីកាលពិតទៅគេគ្រាន់តែដាក់ចេកនឹងហើយនឹងអំបិលដាក់អោយវាតែលោមៗទៅបានហើយ
ពេលនឹងវាចេះតែឆ្ងាញ់ហើយកាលជំនាន់នឹងនោះហើយកាលនឹងនោះ។
និយាយទៅបើគិតទៅវាពិបាកណាស់ព្រោះគិតមើលយើងនឹងខំធ្វើការយ៉ាងចង់ស្លាប់ហើយបែរជាអោយយើងស៊ីមិនគ្រាប់មិនគ្រាន់ចឹងហើយបានថាជាវាមិនសមសោះវានឹងចង់អោយតែយើងនឹងបានស្លាប់តែម្តងបើគិតចឹងហើយធ្វើចឹងនោះមើលទៅចឹងហើយនឹងបានជាមានមនុស្សនឹងស្លាប់ច្រើនយ៉ាងនឹងដោយសារតែអាពតនឹងវាបានធ្វើបាបយើងមិនចេះថាយើងនឹងត្រូវយ៉ាងមិចទេមើលទៅហើយដល់ពេលបានយូរទៅគេថាអត់មានអង្កហើយក៏គេនឹងបានលាយគ្រប់ពោតក្រហមអោយយើងនឹងស៊ីវិញហើយកាលនឹងគ្រាប់ពោតក្រហមទៀតគេយកមកស្ងោរទៅហើយដាក់លាយគ្នាទៅ
ហើយទៅយើងនឹងក៏ដូសហុចចឹងទៅហើយដូចជាមីការភ័ណ្ឌនឹងវាស៊ីមិនកើតក៏យកគ្រាប់ពោតនឹងយកមកបេះសំបកវាហើយស៊ីទៅ ហឺ
ដល់ថ្ងៃនឹងគេបានបបរអោយយើងស៊ីហើយទៅស្រាប់តែស៊ីទៅវានៅសល់នោះចឹងហើយក៏មានអំពង់ទឹកត្នោតប្រវែងរាងវែងដែលនឹងហើយក៏ពេលនឹងយាយនឹងក៏បានប្រាប់ទៅកូនថាកូនអើយបើកូនឯងស៊ីមិនឆ្អែតទេកូនឯងដូសយកទៅផ្ទះទៅ មានណាវាស៊ីឡើងហាល់
ឡើងមកដល់ផ្ទះនឹងឡើងអូសអៀកៗ ហួយ
ចឹងបានថាពេលនឹងសួរគេទៅគេថាវានឹងឆ្អែកពេកហើយក៏ហាល់នឹងហើយហើយកាលនឹងធ្វើមេចបើគេនឹងអោយយើងស៊ី១ឆ្អែកហើយពេលនឹងយើងនឹងវាឃ្លានចឹងហើយស៊ីទាលតែមែនទែនទៅណាកាលនឹងនោះ
ព្រោះឯគិតមើលបើអោយយើងស៊ីមិនគ្រប់គ្រាន់ផងហើយចឹងទៅបានជាចឹងនោះហើយកាលនឹងណាវានឹងអោយនឹងបានតែ១វែកអាក្បាលស្វានឹងទេ
យកបបរនឹងហើយមានអីមានតែទឹកនឹងហើយដ៏ចឹងទៅអ្នកខ្លះគ្មានអីក៏បង្ហូរតែទឹកទៅហើយហាត់តែទឹកទៅក៏មានដែល កាលនឹងវាវេទនាដល់ហើយ
ហើយយើងនិយាយពីត្រកួនវិញខ្លះពួកគាត់ចុងថៅមិនចោលទេសម្លម្ជូរត្រកួននឹងនោះអ្នកចុង

ភៅនឹងមិនព្រមចោលអាម្ខូរត្រកួនៗនឹង
ដល់មែនទែនទៅស៊ីមិនបានហើយក៏ឡើងរោគកើតហើមទៅ អ្នកខ្លះក៏ហើមជើង
ខ្លះទៅក៏ហើមដៃអីចឹងទៅចង់គ្រាប់តែគ្នានឹងហើយនាំគ្នា
ពេលដែលដល់ពេលរដូវខែត្រីនឹងពេលដែលគេបានកាត់ក្បាលត្រីនឹងហើយគេបានបោះចោលទៅហើយចឹងទៅយើងនឹងក៏នាំគ្នាយកក្បាលត្រីនឹងយកទៅជំហុយហើយហុចទៅហូបទៅ បើកាលនឹងវាកើតរោគឡើងហើមហើយនឹងបើស៊ីតែបបរហើយក្នុង១ខ្ទះនឹងបានអង្កតែ៩កំប៉ុងនឹងចឹងបានចឹង ហើយចឹងវាមិនកើតចឹងបានចំលែក ឯងគិតបើចឹងហើយមិនឈឺមិចនឹងកើត។

ក៖ ចុះកាលនឹងយាយបានឈឺដែរឬទេ?

ខ៖
កាលនឹងយាយនឹងអត់អីដែរបើកាលនឹងឈឺហើមនឹងគឺត្រូវជាជីតាថៅឯងនឹងគាត់បានឈឺហើយហើមទៅ
ហើយកាលនឹងណាភាគច្រើនឈឺឡើងហើមនឹងមានច្រើនតែកើតឡើងចំពោះប្រុសៗទេស្រីមិនសូវឃើញមានដែរនឹងហើយបើហើមវិញក៏ហើមរាងតិចដែលកាលនឹងនោះ។

ក៖ ព្រោះកាលនឹងយាយពិសាខមិនបានច្រើនហើយបាក់កំលាំង?

ខ៖ អើ!!!

ក៖ ចុះលោកតាកាលនឹងគេបានប្រើគាត់ទៅណាដែល?

ខ៖
កាលនឹងគេប្រើគាត់ជាប្រុសចឹងគេអោយគាត់ទៅបាចទឹកនៅតំបន់ឆ្ងាយៗទៅបើស្រីៗពលកម្មនៅជិតៗនឹងទៅដើម្បីបានមើលកូនព្រោះកាលនឹងពេលដែលបានធ្វើការងារហើយៗគេអោយស្រីៗនឹងអ្នកដែលមានកូនអោយមកមើលកូនៗខ្លួនឯងវិញ។

ក៖ ហឺ!!កាលនឹងចឹងវាពិបាកណាស់កាលនឹងនោះ។

ខ៖
ហឺ!!ទំរាំតែបានឆ្លងផុតនឹងពេលកំពុងតែស៊ីបាយល្ងាចចឹងគេក៏បានឃើញទាស់សេះបបរមកឡើងលឺសំលេងកុបៗមកហើយកំពុងតែស៊ីនឹងក៏នឹងគិតថាមិនថាជាគេឬជាអញបន្ទាប់មកទៀ

តទេ។ស្រាប់តែមកចុចហៅឡើងអាទេសសេះទៅៗហើយទៅបាត់រហូរចឹងទៅព្រោះអ្នកដែលគេបានហៅនឹងសុទ្ធតែគេបានកត់ដាក់ឈ្មោះនៅក្នុងក្រដាសគេអស់ហើយ។

ក៖ ចុះគេយកពួកគាត់ទៅណាដែរ?

ខ៖ គេយកទៅសំលាប់ចោលណាថៅ។

ក៖
ហើយចឹងកាលនឹងយាយបានមើលឃើញអាពតបានយកមនុស្សទៅសំលាប់ចោលដោយផ្ទាល់ភ្នែកដែលឬទេ?

ខ៖ ចាស!
បានឃើញគេមកហៅកន្លែងសហាករគេចឹងទៅណាព្រោះអោយតែពេលល្ងាចឡើងនឹងឃើញរទេះគេមកហើយមានរទេះសេះនឹងយើងនឹងបារម្ភមិនបានដឹងថាជាគេឬក៏ជារូបឯទេកាលនឹងនោះ ឃើញតែគេនឹងហៅទៅៗបាត់អស់។

ក៖ ហើយកាលនឹងគេហៅហើយចេះតែទៅតាមគេទៅ?

ខ៖
អើ!!កាលនឹងគេហៅមិនទៅមិនបានយើងរត់ក៏រត់មិនកើតដែលតែគេហៅហើយយើងត្រូវទៅមួយនឹងគេនឹងតែម្តងហើយយើងមិនអាចរត់ទៅណាកើតទេព្រោះរត់វាមិនរួចចឹងចេះទៅៗបាត់ៗទៅមិនឃើញវត្តសំបូរមាសទេគេបានឃើញសុទ្ធតែក្បាលសពព្រោះកាលនឹងគេបានយកពួកគាត់ទៅសំលាប់ចោលនៅឯទីនោះនឹងតែម្តង នៅឯវត្តសំបូរមាសនឹងហ៎។

ក៖ ចាស! ហើយចឹងយាយពិតជាភ័យមិនស្ទើរទេចឹងហើយកាលនឹងនោះ?

ខ៖
អារឿងភ័យនឹងវាភ័យបារម្ភហើយព្រោះកាលនឹងគេបានដាក់ងារអោយយើងនឹងវាជាពួកមូលធន ជាអ្នកដែលមានធននៅកណ្តាលចឹងហើយ
ហើយចេះតែបារម្ភចឹងហើយព្រោះថាប្រវត្តិគេអ្នកមូលធននឹងពីសង្គនឹងជាអ្នកគឺជាអ្នកដែលជិះជាន់គេព្រោះបានប្រើគេចឹងហើយណា តែយើងមិនបានទៅជិះជាន់អី
ព្រោះថាកាលនឹងយើងបានធ្វើចំការអីចឹងទៅពេលដែលយើងនឹងធ្វើវាមិនទាន់ចឹងទៅក៏ហៅ

គេមកអោយជួយ
ហើយគិតអោយគេក្នុង១ថ្ងៃចឹងប៉ុន្មានដូចជា៥០០០រអីចឹងទៅបានអោយគេចឹងទៅ អោយគេមកធ្វើចឹងទៅថៅរួចទៅយើងបានដាំទឹកដាំបាយអោយគេនឹងស៊ីទៅហើយគ្រាន់តែចឹងដែរ ក៏វាគិតថាយើងនឹងជិះជាន់កំលាំងពលកម្មគេដែល
ហើយចឹងទៅជាហៅយើងនឹងជាអ្នកមូលធនហើយដែលគេថាពួកថ្នាក់កណ្ដាលនឹង
ហើយចឹងទៅបានជាគេថាពួកនឹងគេបានបែងចែកសម័យនឹងជា៣វណ្ណៈគឺពួកមូលធននឹងពួកថៅកែ
នឹងពួកអ្នកនេះនឹងគេហៅថាថ្នាក់កណ្ដាលហើយបើអាឋានៈមួយទៀតនឹងគេលើដំកើនណាស់ គេយកអ្នកដែលប្រវត្តិក្រៗនឹងគេអោយទៅយកដាក់មើលការខុសត្រូវនៅនឹងឃ្លាំងតែម្ដងនឹងនឹងហើយពួកនឹងបែរជាបានធ្វើការងារល្អហើយគេថាមកពីពួកនឹងគេមានប្រវត្តិល្អ។

ក៖
អូ!!នឹងយាយបានឆ្លងកាត់បទពិសោជន៍ច្រើនណាស់ចឹងហើយចឹងតើយាយនឹងមានការចង់ចាំនៅក្នុងជីវិតរបស់លោកយាយថាតើលោកយាយមានបទពិសោធន៍ល្អៗដែលឬទេលោកយាយ?

ខ៖
ការនឹងយាយនឹងគ្មានបានគេធ្វើបាបអីទេព្រោះកាលនឹងយាយនឹងវាមិនមែនជាអ្នកឯរស់នៅទីក្រុងភ្នំពេញចឹងហើយគេនឹងធ្វើបាបតែអ្នកដែលជំលាស់ពីភ្នំពេញទេ
ហើយអ្នកដែលជំលាស់មកនឹងគេហៅថាប្រជាជនថ្មី
ហើយប្រជាជនថ្មីនឹងគេមកនៅជាមួយនឹងយើងដែលជាប្រជាជនចាស់ហើយដ៏ពេលដែលមានបញ្ហាអីគេយកប្រជាជនថ្មីនឹងទៅសំលាប់ចោលមុនគេហើយ ហើយគេយកសំលាប់ចោលហាំ

ក៖ គេយកទៅសំលាប់ចោលមុនគេ?

ខ៖ អឺ!! គេយកទៅមុនគេហើយនឹង។

ក៖ ហឺ!!អាក្រក់មែស?

ខ៖
អើ!!!ហើយទៅឯងនឹងវានឹងអាណិតជាគេនឹងគឺគេបានយកនារីៗពេញៗវ័យនឹងគេយកទៅជា

ក់១ជុំទៅហើយចាស់ៗនឹងគេយកទៅដាក់១ជុំដែលចឹងទៅ
ហើយពួកឪពុកម្ដាយរបស់ពួកនារីពេញវ័យនឹងគេយកទៅដាក់នៅជាមួយនឹងប្រជាជនចាស់ចឹងទៅណា
ហើយដូចជានារីៗវ័យដូចជាឯងនឹងគេបានយកទៅកាប់១ជុំទៅហើយគេយកទៅរែកដី
ហើយបន្ទាប់មកគេនឹងយកទៅរែកដីដូចជារែកនៅភ្នំអីណាន់
ចឹងហាំហើយយកទៅរែកៗនឹងអីមទៅមើលទប់នុបនឹងឥឡូវនឹងនៅទាល់ឥឡូវដោយសារពួកនាក់ដែលមកពីប្រជាជនដែលថ្មីនឹងហាំ ដែលគេបានប្រើទៅលើកដីទំនប់នឹងនោះ។

ក៖ ចាស!ហើយសព្វថ្ងៃនឹងទំនប់នឹងមានទីតាំងនៅកន្លែងណាដែលលោកយាយ?

ខ៖ ទប់នុយឯន់ គេហៅថាជាទំនុបអីតាយានអីន់កាលពីដើមនឹងគេជិះទៅឯប្រាសាទឯណាំអូស ហើយរែករួចហើយយកគ្នាទៅសំលាប់ចោលអស់រលីង ពួកនារីៗនឹងហាំ
ហើយនឹងពួកយុវជនប្រុសៗដែលនឹងដែលបានមកពីភ្នំពេញនឹងណា។

ក៖ ចាស!!

ខ៖
ហើយវាបានប្រើរួចទៅវាបានយកទៅសំលាប់ចោលអស់ពួកដែលគេជំលៀសពីភ្នំពេញនឹងន់ចឹងបានងាប់ច្រើនណាស់នឹងណា។

ក៖ ហើយចឹងស្ដាយមែនទែនពួកគាត់សុទ្ធតែពេញកំលាំងហើយ
ចឹងកាលនឹងយាយមានសំណាងដែលបានរួចជីវិតនឹងអត់អី។

ខ៖ អើអានឹងវាថាមិនអីដូចថាយើងនឹងជាអ្នកនៅក្នុងស្រុក
ចឹងទៅចេះតែយកចិត្តគេទៅមានៅថាពេលដែលគេហៅទៅណាទៅតាមគេទៅព្រោះវានឹងយាយនឹងមិនបានប្រឆាំងនឹងគេទេចឹងហើយវាចេះតែមានរួចជីវិតហើយទៅក៏បានរស់មកដល់សព្វថ្ងៃនឹងនោះហើយមួយទៀងនឹងយើងនឹងចេះយកចិត្តគេផងបើមិនចឹងទេគេយកទៅសំលាប់ចោលដូចតែគ្នានឹង។

ក៖
ចាស!ចឹងយាយកាលបានយកចិត្តគេយ៉ាងម៉េចដែលទេ?ដូចថាគេប្រើយាយអោយធ្វើអ្វីក៏ធ្វើទៅ?

ខ៖ អើកាលនឹងគេប្រើអីយើងធ្វើទៅណា។

ក៖
ចឹងកាលនឹងពេលដែលជំនាន់អាពតនឹងពេលដែលយើងលំបាកជាងគេនឹងគឺនៅជំនាន់អាតគេមិនសូវបានអោយអាហារគ្រាប់គ្រាន់ចឹងទេអីលោកយាយន៎?

ខ៖
នឹងហើយកាលនឹងលំបាកជាងគេនឹងយាយនឹងបានគេអោយអាហារបន្តិចមកស៊ីហើយស៊ីនឹងវាមិនបានគ្រាប់គ្រាន់ដល់ចឹងហើយបានជាយាយនឹងឡើងបាក់កំលាំងហើយវាពិបាកខ្លាំងតែអ្នកដែលលំបាកជាងគេនឹងគឺអ្នកដែលបានគេជំលៀសពីភ្នំពេញទេដែលលំបាកជាងគេដល់មែនទែនទៅដល់តែមក
យាយបានលឺគេយាយគេអោយពួកអ្នកនៅភ្នំពេញនឹងគេបានប្រាប់ថាអោយចេញ១រយៈសិនទៅហើយពួកនឹងខ្លះទៅគ្មានបាននឹងយកអីទៅជាមួយណាព្រោះគ្មានឹងមិនបានប្រុងប្រៀបអីយកមកអ្នកខ្លះក៏បានដោយមាសខ្លះនឹងយកមកដល់ចឹងមានអីមានតែមាសហើយខ្លះទៀតនឹងក៏មាននាឡិកាអីចឹងទៅហើយក៏បានដូរអ្នកស្រុកនៅនឹងដូចជាបានដូរអង្កអីសំរាប់ស៊ីអីចឹងទៅណា ហ៎ី។

ក៖ កាលនឹងគេធ្លាប់បានមកដូរយាយដែលឬទេ?

ខ៖
អត់ទេកាលនឹងព្រោះយាយនឹងនៅមានជីតាជីដូនដែលពួកគាត់នឹងនៅក្នុងបន្ទប់ហើយដំពេលដែលធ្វើស្រែបានហើយទុកទំនុបបំរុកសំរាប់ពួកគាត់
តែចំពោះគេដែលមានហើយគ្មានជីដូនជីតានៅជាមួយចឹងគេក៏ចេះតែដូរបានចឹងដែរនឹងប៉ុន្តែយាយនឹងមិនបានដូរអីនឹងគេទេព្រោះយាយមានជីដូនជីតានឹងពួកគាត់ចាស់ៗអស់ហើយដល់នឹងទៅយាយនឹងវាមិនហ៊ានដូរទេ ទុកសំរាប់គាត់

តែដល់ពេលដែលបានទុកហើយនឹងស្រាប់តែគេថាដល់ពេលដែលគេនឹងនេះរួចទៅគេថាអោយយើងនឹងចូលជាបាយរួមវិញដល់ចឹងទៅគេបានប្រមូលទៅដាក់សហាករគេអស់។

ក៖ អឺមចឹងអត់ទៅ....

ខ៖ អើ!ចឹងគេបានដើរប្រមូលអស់ហើយគេគ្មានបានអោយយើងទេ ហើយកាលនឹងគេបានអោយទៅស៊ីបាយរួមឯនោះគេគ្មានបានអោយយើងននោះទេ ហើយកាលនឹងយាយនឹងបានយកអោសយគេអស់ហើយកាលនឹងនោះ។

ក៖ អើ!!! កាលនឹងចឹងយាយនឹងមិនបានមានរបស់ពីដើមបានទុកជារបស់ខ្លួនឯងឡើយ?

ខ៖
អើយ!កាលនឹងអត់មានទេព្រោះកាលនឹងគេមិនបានអោយយាយនឹងទុកនៅនឹងផ្ទះទេព្រោះគេបានអោយទៅប្រមូលដាក់នៅនឹងសហាករអស់ហើយនឹងចៅអើយ ហើយពេលនឹងនោះយាយនឹងបានខំកប់ចានអីនឹងនៅក្នុងដីឯនោះបានហើយនឹងតែស្រាប់តែគេថាចឹងក៏បានយកទៅអោយគេយកទៅដាក់នៅសហាករនឹងអស់វិញទៅ ពេលនឹងយាយនឹងស្តាយណាស់ព្រោះយាយនឹងបានខំទុកវាបានមកអស់រយៈពេលយូរដែលហើយនឹងបានស្រាប់តែគេថាអោយយើងនឹងត្រូវទោដាក់នៅសហាករគេចឹងបើគេនឹងរកឃើញនៅផ្ទះនរណាគេនឹងគេនឹងយកយើងនឹងទៅសំលាប់ចោលមួយពូជជាមិនខាន ហើយបើនិយាយពីបើថាគេបានឃើញថាផ្ទះណាននឹងមានផ្សេងអីនឹងបើគេឃើញនឹងគេនឹងសំលាប់ចោលហើយគេមិនអោយមានផ្សេងអីនៅផ្ទះទេព្រោះកាលនឹងគេដឹងថាមានផ្សេងគឺមានន័យថាយើងនឹងបានលួចដាំបាយឬធ្វើអ្វីសំរាប់ញុំាអីចឹងហើយបានជាគេហាមមិនអោយមានផ្សេងនៅផ្ទះនោះអី។
ហើយបើចានអីនឹងក៏ដោយបើថាមានត្រូវយកទៅដាក់នឹងសហាករនឹងទៅទាំងអស់នឹងហើយបើថាមានវិញនឹងគេនឹងយកទៅសំលាប់ហើយ
ហើយបើថាយើងនឹងហ៊ានយករបស់របរនឹងលាក់ទុកវិញយើងនឹងត្រូវបានគេរកឃើញដែលនឹងយើងនិងមានបញ្ហាជាមួយនឹងគេព្រោះគេបានប្រាប់យើងហើយតែយើងល្មើសនឹងគេដឹងតែយកយើងនឹងទៅសំលាប់ចោលមួយពូជជាមិនខាន។
ហើយចឹងហើយចឹងយាយនឹងក៏បានមកដេកគិតហើយពេលនឹងយាយនឹងបានយកចាននឹង

ទៅលាក់ទុកបានជាច្រើនដែលនឹងតែស្រាប់តែគេថាចឹងហើយចឹងយាយនឹងក៏បានទៅរកវិញពីកន្លែងដែលយាយនឹងបានយកទៅកប់នឹងហើយខំរកនឹងរើសយកមកអោយគេវិញទាំងអស់នឹង។
ហើយកាលនឹងនោះគេនឹងវានឹងគ្មានទៅដឹងទេព្រោះកាលនឹងវានឹងបានតែគំរាមយើងនឹងវាធ្វើចឹងទៅដើម្បីអោយយើងនឹងភ័យខ្លាចចឹងហើយបានជាងវាអោយយើងនឹងខ្លាចចឹងបានជាយើងនឹងបានកប់ហើយគាស់អោយវាវិញរួមមានទាំងថ្នឹលអីនឹងព្រោះកាលនឹងយាយនឹងបាននឹកឃើញថាបើរបរនឹងវាកើតមកជាក្រោយទេតែបើជីវិតយើងវិញនឹងវានឹងបាត់ហើយនឹងបាត់រហូតហើយចឹងទៅបានជាយាយថាទៅយកទៅអោយវាទៅព្រោះរបស់របរនឹងវាកើតមកតាមក្រោយទេអោយតែយើងនឹងនៅមានជីវិតយើងនឹងអាចរកវាបានមកវិញជាមិនខានឡើយ។
ហើយអីនឹងយាយបានយកទៅដាក់រលីងហើយនរណាមានអីកាលនឹងយកទៅដាក់ទាំងអស់គ្មានផ្ទះណាមានអីទេកាលនឹងនោះនៅតែសំបកផ្ទះហើយមើលទៅនៅតែផ្ទះនឹងឡើងទទេរស្អាតទៅណាស់។
ហើយពេលនឹងយាយនឹងបានដេកគិតដេលថាបើយើងនឹងមិនបានគាស់ទេចឹងខ្លាចតែដល់ពេលដែលវានឹងរកឃើញវាបានយកយើងនឹងទៅសំលាប់ចោលមួយពូជចឹងទៅធ្វើយ៉ាងម៉េចទៅចឹងហើយព្រោះកាលនឹងវានិយាយប្រាប់យាយដើរប្រាប់គេប្រាប់ឯងអស់ហើយកាលនឹងនោះយាយនឹងចេះតែគិតហើយនឹកៗទៅដដែលៗថារបស់នឹងវាកើតក្រោយទេចឹងទៅហើយរកបានមកវិញទេមិនចឹង?

ក៖ ចាស ត្រូវហើយ។

ខ៖
អើ!ចឹងទៅក៏នាំគ្នាប្រមេលប្រមូលទាំងអស់នឹងហើយទៅបានជាបានចូលបាយរួមនឹងហើយគេនឹងវាបានប្រមូលអស់រលីងគ្មានបាននៅសល់អីត្រង់ណាទេ
ហើយពេលនឹងយាយនឹងឃើញគេបបរអោយយើងស៊ីបានតែបន្តិចព្រោះនៅក្នុងបបរក្នុង១ខ្ទះនឹងគេបានដាក់តែអង្ករតែ៤កំប៉ុងនឹងគ្មានអីស៊ីទេ ហើយអោយយើងនឹងខំធ្វើស្រែធ្វើអីចឹងទៅអោយចេះតែខំហើយដូចជាអោយយើងនឹងខំប្រឹងបាច់ទឹកស្រូវទឹកអីចឹងទៅហើយអោយយើងនឹងទៅណាទៅនែចឹងទៅដើម្បីធ្វើការងារអោយគេ

តែពេលដែលខំប្រឹងធ្វើការងារចឹងហើយនឹងគេនឹងមិនបានអោយយើងស៊ីបានគ្រាប់គ្រាន់ទៀត ចៅឯងគិតមើល ។

ក៖ ចាសកាលនឹងគេបានធ្វើបាបយើង។

ខ៖ ហើ!!! ចឹងហើយនឹងបាបជាមានមនុស្សជំនាន់នឹងបានស្លាប់ច្រើននឹងចឹងទៅ។

ក៖ ហើយចឹងកាលនឹងពេលដែលយាយកាលនឹងមានបានមេកងគេធ្វើបាបយាយទេ?

ខ៖
ហើយកាលនឹងនោះមេកងនឹងវានៅក្នុងភូមិជាមួយនឹងយាយដែលតែប៉ុន្តែបន្ទាប់មកទៀតនឹង គេបានអោយទៅណាទៅនៃនឹងហើយពេលដែលដាច់អាពតមកនឹងពួកដែលធ្លាប់ជាមេកងនឹង រត់ទៅនៅស្រុកគេអស់ចឹងទៅគ្មានហ៊ាននៅក្នុងស្រុកណាខ្លាចគេដែលនឹង។

ក៖ អូ!!!ចឹងពួកគាត់មិនបាននៅនឹងស្រុកកំណើតរបស់ខ្លួនបន្តទេ?

ខ៖
អើ!កាលនឹងគេនាំគ្នារត់ចេញទៅអស់ចឹងទៅព្រោះខ្លាចគេនឹងវៃគាត់វិញនឹងព្រោះគ្មាននរណា គេចូលចិត្តគាត់នឹងទេព្រោះកាលនឹងជំនាន់អាពតនឹងគាត់បានអោយគេធ្វើបាបគេដោយអោ យគេធ្វើការងារច្រើនដែលនឹង។

ក៖ ហើយយាយកាលនឹងនោះតើមានមេកងនឹងប៉ុន្មាននាក់ដែរទៅយាយបានដឹងដែរឬទេ?

ខ៖
កាលនឹងយាយមិនបានដឹងអីទេព្រោះកាលនឹងយាយនឹងមិនដឹងថាគេចាត់តាំងនៅប៉ុន្មាននាក់ ទេដូចជាមានកងអាពត កងកុមារ ហើ
មិនបាត់និយាយថាប៉ុន្មាននាក់នោះទេព្រោះកាលនឹងនោះគ្មាននរណាគេទៅសង្កេតថាមានមេ កងប៉ុន្មាននាក់នោះទេ
ព្រោះកាលនឹងនោះតែដល់ពេលដែលព្រលឹមឡើងនឹងគេនាំគ្នាទៅធ្វើការអស់ហើយ
ហើយដល់ពេលប្រលប់វិញមើលទៅរាងល្ងាចនឹងគេនាំគ្នាមកផ្ទះគេវិញអស់ហើយណាចៅអើ យ។

គេបានអោយយើងនឹងចូលកន្លែងគេទៅគេនឹងផ្សេងទៅហើយយើងនឹងនៅផ្សេងពីគ្នាដែលចឹងទៅ។

កៈ
ហើយចឹងកាលនឹងយាយមានបានដឹងទេថាកាលនឹងយាយបានស្គាល់គេឬកំណត់សំគាល់ថាគេជាមេកង់នឹងដោយរបៀបណាដែល?

ខៈ កងនឹងមើលទៅវាដូចតែ
សន្តិសុខនៅសម័យនឹងចឹងដែលនឹងណាដូចសព្វថ្ងៃនឹងដូចថាពេលដែលមាន១ថ្ងៃចឹងគេបានតាំង១កន្លែងចឹងទៅ។

កៈ កាលនឹងគេស្លៀកសំលាក់បំពាក់ដូចនឹងយើងធម្មតាដែរឬទេ?

ខៈ អើ!កាលនឹងស្លៀកពាក់ដូចគ្នាទេតែកាលនឹងនោះគេបានប្រាប់ដែរថាអ្នកនេះនឹងជាមេកងគេបានប្រាប់ថាចឹង។

កៈ ចាស! ចាស!

ខៈ អើ! ណានឹងវាចឹងតែគេមិននេះទេ
ម៉េចៗតែគ្នាគេយើងមិនបានដឹងអីទេកាលនឹងនោះថាថ្ងៃណាគេនឹងយកអ្នកណាទៅសំលាប់នោះយើងគ្មានទៅដឹងទេរឿងនឹងនោះគេមិនបានប្រកាសអោយយើងបានដឹងនោះទេគេធ្វើការនឹងដោយគ្នារបស់គេនឹងយើងចាំតែគេបរទេះសេះមកហៅចុចឈ្មោះទៅនឹងអ្នកខ្លះទៅមិនបានទាំងដឹងថាខ្លួននឹងមានកំហុសអីផងបានជាគេយកយើងទៅនោះ។
ហើយយើងវិញមានបានដឹងត្រឹមតែព្រលឹមឡើងចេញទៅធ្វើការហើយដល់ពេលល្ងាចឡើងនឹងចូលផ្ទះវិញតែប៉ុននឹងនោះ។
ហើយពួកមេកងនឹងហើយដែលបានស៊ើបគ្នាឯថាតើម្នាក់នឹងគេបានធ្វើអីហើយដោយសារពួកនឹងហើយដែលរាយកាលហើយយកពត៍មាននឹងទៅប្រាប់អ្នកខាងលើហើយបានជាគេនឹងចុចឈ្មោះហៅអ្នកនឹងទៅ
ហើយពេលនឹងបើគេនឹងបានស៊ើបការឬក៏សំភាសន៏ចឹងទៅគាត់បានលាក់មិនបានប្រាប់កាលពិតនឹងក៏គេមិនបានដឹងទេប៉ុន្តែបើគេបានដឹងនឹងគឺដោយសារតែអ្នកដែលនៅជាមួយនឹងគ្នានឹងចឹងហើយពេលនឹងពួកនឹងបានទៅសួរអ្នកជិតៗពីគាត់ហើយតើគាតពីមុនឡើយនឹងមានការងា

រជាអ្វីហើយបានគេដឹងនឹងដោយសារចឹងទេ
ពេលខ្លះទៅគេមិនបាននឹងសួរទៅអ្នកនឹងផ្ទាល់ទេខ្លាចគេនឹងដឹងហើយយកទៅសំលាប់ចោល
ចំពោះអ្នកដែលមានមុខរបរល្អដែលមានមុខនៅក្នុងមន្រីរាជការនោះ
ហើយគេលួចសួរថាពេលអ្នកដែលនៅភ្នំពេញនឹងតើអ្នកបានធ្វើការងារឬមុខរបរជាអ្វីដែល?
ហើយគេបានប្រាប់ថាបើមានអ្នកណាគេធ្វើគ្រូហើយប្រាប់គេវិញទៅគេនឹងអោយយើងនឹងធ្វើ
ការងារដំដែល។

ក៖ ហឺ!!!

ខ៖ អើគេបានប្រាប់យើងថាចឹងហ៎
ស្រាប់តែគ្រូមួយនឹងគាត់បានធ្វើគ្រូកាលនៅពីដើមនឹងចឹងគាត់បានប្រាប់គេថាគាត់ជាគ្រូបង្រៀ
ន
គាត់និយាយប្រាប់គេថាចឹងថាខ្ញុំកាលពីដើមនឹងធ្វើជាគ្រូដល់ចឹងហើយមានអីគេដឹងហើយថា
គាត់នឹងធ្លាប់បានធ្វើគ្រូវដល់ចឹងទៅគេបានហៅគាត់ទាំងយប់ទៅ
គេហៅទៅវៃចោលទាំងយប់នឹងម៉ង់ចឹងហ៎ បានចឹងនឹង។

ក៖ ចាសចឹងកាលនឹងនៅក្នុងឆ្នាំណាដែលនៅជំនាន់អាពតនឹងនោះ?

ខ៖
អើកាលនឹងវាស្ថិតនៅក្នុងជំនាន់អាពតនឹងហើយបានជាមានកាលបែបនឹងកើតឡើងនោះ។

ក៖ ចាសតែ..

ខ៖ អើ!! កាលនឹងវាបានចឹងហើយនឹងសម័យប៉ុពតនឹងវាខុសគ្នាត្រង់នឹងសម័យលុន
ណាល់ពេលនឹងគេបានផុតសម័យលុន ណាល់នឹងក៏បានចូលដល់សម័យពពតនឹង
ហើយកាលនឹងយាយនឹងទាន់ទាំង២សម័យនឹងកាលនឹងសម័យពីនឹងវាខុសគ្នាត្រង់សម័យលុ
ន
ណាល់នឹងគេបានទំលាក់គ្រាប់បែកចំពោះអ្នកដែលជាទាហ៊ាននៅភ្នំពេញចឹងទៅណាហើយចំ
ណែកឯអ្នកនៅឯជនបទវិញគេនឹងជាអ្នកដាក់គ្រាប់បែកនៅក្នុងព្រៃហើយពួកនឹងហើយដែល
នៅជាមួយប្រជាជនកាលនឹងនោះវាចឹងឯង
ហើយគេហៅថាពួកពពតដែលនៅក្នុងព្រៃនៅក្នុងស្រុកនឹង

ហើយពួកឈ្មោះមួយទៀតនឹងគេបានហៅថាពួកយ៉ាក់មិនហើយគេនឹងបានធ្វើនយោបាយខ្លែងបន្លំថាមើលទៅដូចជាពួកវានឹងល្អហើយយើងនាំគ្នាថាអូពួកនឹងល្អ អូស ហើយថាមើលតែមេស១ផ្លែគេមិននឹងបេះរបស់យើងផង។
មុនដំបូងនឹងគេធ្វើជាល្អជាមួយនឹងយើងណាស់ចឹងណា ហើយនិយាយពីពួកលន់ណល់អីនឹងដែលជាអ្នកទំលាក់គ្រាប់បែកមកហើយគេនៅតាមខេត្តអីចឹងទេ ហើយថាពួកដែលនៅឯតាមស្រុកអីនឹងគេថាពួកអាពតទេ ហើយនេងគេហៅថាពួកពពតចឹងហើយ ហើយពួកនឹងនឹងមិនហ៊ានចូលមកទេបើពួកលន់ណល់នឹងចូលមកនឹងម្តងៗនឹងទាល់តែមានទាហាននឹងកងហើយមានយន្តហោះមកជាមួយដែលចឹងបានជាគេមក
ហើយបើថាចង់ចូលមកត្រង់ចឹងដូចជាចូលមកនៅឯពាមក្នុងអីចឹងទៅណាចឹងហើយបានមកទាល់តែគេនឹងបានមកជាមួយនឹងកងទ័ពនឹងមានយន្តហោះអីមកជាមួយដែលបានជាគេហ៊ានចូលមកមើលអ្នកស្រុកកើត ហើយថាបើមកវាមិនត្រូវនឹងជួបគ្នាវិញវៃគ្នាគ្រុងវៃគ្នាប្រាវឥឡូវនឹង ហើយបើថាយើងជាអ្នកស្រុកវិញចង់ទៅខេត្តវិញនោះត្រូវតែដើរកាត់តាមផ្លូវវៀងវិញមិនមែនដើរតាមផ្លូវត្រង់ទេដូចជាផ្លូវជាតិទេព្រោះកាលនឹងនោះវាបានកាប់ខ្នុរអីឡើងខូចចង់អស់ហើយកាលនឹងនោះ។

ក៖ អូលចឹងកាលនឹងពួកគាត់នឹងបានទៅកាប់ខ្នុរទៀត?

ខ៖
អើ!យឺកាលនឹងវាបានកាប់ខ្នុរកាលនឹងកាប់ហ៎ផ្តាចៗអស់រលីងព្រោះខ្លាចពួកទាហ៊ាននឹងបានចូលមកព្រោះនៅក្នុងស្រុកនឹងពួកពពតនឹងគេខ្លាចពួកយ៉ាក់មិនអីនឹងបានចូលមកដល់ចឹងហើយបានជាពួកនឹងនាំគ្នាទៅកាប់ដើម្បីការពារមិនអោយពួកនឹងចូលមកក្នុងស្រុកទេព្រោះពួកពពតនឹងវានៅបង្កប់ជាមួយបនឹងអ្នកស្រុកនឹងតែចំណែកឯពួកយ៉ាកមិននឹងគេនៅតាមខេត្តទេគេមិនហ៊ានចូលមកនៅតាមស្រុកជាមួយនឹងប្រជាជននោះទេផ្តេសផ្តាស់នោះទេបើថាមានម្នាក់១នាក់ទៅ២នាក់អីហ៊ានចូលមកនោះគេនឹងបាត់ខ្លួនឥឡូវហើយនឹង។

ក៖ ព្រោះកាលនឹងអាពតនឹងបានដាក់មីដាក់អីដែលកាលនឹងនោះ។

ខ៖ អឺ!កាលនឹងពួកអាពតនឹងវាបានដាក់មីុនដាក់អីដែលនឹងកាលនឹងនោះ
នៅនឹងតាមផ្លូវសំខាន់ៗនោះហើយបើថាហ៊ានតែចូលមកនឹងគេនឹងផ្ទុះស្លាប់មិនខាតទេហើយ
ផ្ទុះអីចឹងស្លាប់អស់ទៅ
ហើយចឹងបានថាពួកអ្នកស្រុកនឹងកាលនឹងរៀបចេញទៅខេត្តកំពង់ចាមថាបើចង់ទៅទិញឥវ៉ាន់
អីនឹងត្រូវតែរកផ្លូវដើរវាងគេមិនខានបើមិនចឹងទេនឹងត្រូវដើរទៅជាន់មីុនស្លាប់ដែលនឹងមិនខាន
ដែលនឹងឥឡូវហើយ
ហើយដល់ចឹងទៅគេអ្នកស្រុកយើងនឹងក៏បានរើសយកផ្លូវទឹកជិះទៅកាត់តាមព្រៃខ្លះកាត់ឡើង
ទៅដល់នឹងខេត្តយើងនឹង។

ក៖ ការនឹងយាយចាំទេថានៅនឹងម្តុំផ្ទះលោកយាយនឹងគេមានបានដាក់មីុនដាក់អីដែលឬទេ?

ខ៖ កាលនឹងនោះគ្មានទេគេមិនបានមកដាក់មីុននៅនឹងម្តុំផ្ទះនឹងទេ
គេបានដាក់នឹងគេដាក់សំរាប់តែតាមផ្លូវលំអីចឹងទេគេដាក់ដូចជានៅតាមផ្លូវលំ
តាមផ្លូវជាតិអីចឹងដែលនឹងបានជាគេដាក់នោះ ហើយជាផ្លូវធំអីចឹងទេ។

ក៖ អូ! ចាស!

ខ៖
ហើយបើថាទៅនៅម្តុំផ្ទះយាយនៅនឹងវាផុតហើយគេមិនបានដាក់គ្រាប់បែកនៅក្នុងម្តុំនឹងទេ
ចៅ គ្មានទេព្រោះសុទ្ធតែអ្នកស្រុកចឹងហើយកាលនឹងគេមិនបាននឹងទៅដាក់ទេ
ព្រោះអីកាលនឹងពួកអាពតនឹងវានៅជាមួយនឹងពួកយើងដែលនឹង
បើមាននឹងមានតែវាទំលាក់គ្រាប់បែកទេបានមានទំលាក់មកពីពួកលន់ណល់ដែលគេបានទំ
លាក់ពីលើមកខាងឯយន្តហោះនោះទេចៅ។ កាលនឹងមានទាំងលុន
ណល់ផងហើយនឹងពួកអាពតផងវានឹងមាននៅខ្មែរយើងនឹងដូចគ្នានឹងតែវាបានបែងចែកពួក
ជា២ចឹងវាមានពួកលុនណល់នឹងហើយពួកអាពតនឹងឯចៅ
ហើយយាយនឹងទៅពួកពពតនឹងវាឆ្លាតណាស់ព្រោះវាបានជ្រើសយកកន្លែងនៅជាមួយនឹងអ្ន
កស្រុកហើយពួកលន់ណល់វិញមិនបានសូវហ៊ានចូលមកអីតែគេនឹងគេមានសុទ្ធតែអាវុធល្អជា
ងពួកអាពតដូចជាយន្តហោះហើយគ្រាប់បែកនិយាយទៅវាពូកែយុទ្ធម៉្យាងម្នាក់ដែរ។
ហើយម៉្យាងទៀតនឹងនិយាយពីពួកទាហានវិញក៏មិនបានហ៊ានចូលមកដែលព្រោះខ្លាចត្រូវជា

ប់កំដាប់ដៃពួកអាពតនឹងពួកទាហាននឹងគេនៅតែក្នុងខេត្តទេមិនហ៊ាននឹងដើរឬចូលមកនៅក្នុងស្រុកជាមួយនឹងប្រជាជននឹងទេលឺនៅពួកនឹងហើយវាមិនហ៊ានទេ
ហើយដំចឹងហើយទៅបានជាគេឃើញមានពួនឹងហើយដែលជាមានការវៃគ្នានោះ។

ក៖ ចឹងកាលនឹងយាយបានឃើញគេវៃគ្នាដែរឬទេ?

ខ៖
អើ!!កាលនឹងយាយបានឃើញគេវៃគ្នាដែរតើតែកាលនឹងមិនបានមើលនឹងភ្នែកផ្ទាល់ទេតែយាយបានលឺសំលេងកំភ្លើងនៅឯព្រៃទទឹងឯណោះលឺមកដល់នឹងហ៎កាលនឹងដល់ពេលចឹងទៅពួកយើងនឹងអោយតែដឹងហើយលឺសំលេងកំភ្លើងចឹងមានបានដឹងថាគេនឹងវៃគ្នាហើយដល់ចឹងទៅត្រូវតែរត់ចូលទៅពួននៅក្នុងរន្ធដៅត្រង់សុងឯនោះព្រោះកាលនឹងយើងត្រូវតែជីកដីធ្វើជារន្ធដៅនៅក្បែរផ្ទះនឹងហើយនឹងឆ្ងាយពីផ្ទះរាងៗខ្លួនបន្តិចព្រោះដល់ពេលគេទំលាក់គ្រាប់បែកមកយើងនាំគ្នាទៅច្រកនៅក្នុងរន្ធដៅនឹងឯ
ដល់ហើយពេលដែលលឺថាគ្គុងចឹងទៅត្រូវតែចូលទៅក្នុងរន្ធដៅត្រង់សុងផ្ងៀមហើយពេលនឹងនោះយាយបានលឺសូរអោយតែវឺលមកនឹងហើយដឹងតែសំលេងបន្ទាប់ទៀតនឹងគឺលឺថាគ្គាំងហើយថៅអើយ ព្រោះវាបានធ្លាក់ដល់ដីនឹងហា
គិតមើលវានឹងបានបាញ់អាកំភ្លើងធំវានឹងមកនៅត្រឹមតែព្រៃទទឹងសោះស្រាប់តែមកដល់នឹងយើងលឺដែលនឹងហើយសំលេងនឹងណាវាលឺខ្លាំងតែយើងនឹងមិនដឹងថាវានឹងទៅធ្លាក់នៅឯណាឬម្តុំណាទេកាលនឹងអាកំភ្លើងធំគេនឹងប្រហែលជាធ្លាក់មកនៅក្នុងចំងាយជាង៦ទៅ៧គីឡូរបស់គេដែលនឹងគ្រាប់អាកាំភ្លើងដែលគេបានបាញ់មកនឹងដែលនឹងណាហើយលឺតែសូរឡើងគ្គឹងភ្លាមចឹងណាយើងនឹងរត់ចូលក្នុងរន្ធដៅហើយ
ព្រោះដឹងតែលឺចឹងវានឹងទំលាក់គ្រាប់មកទៀតហើយតែយើងមិនបានដឹងថាគ្រាប់នឹងនៅឯណាតែប៉ុននឹងហើយពេលជំនាន់នឹងអ្នកស្រុកនៅម្តុំជិតៗគ្នានឹងណាមិនហ៊ានដើរផ្ទះនៅជិតៗគ្នានឹងទេណាមើលទៅដូចជានៅឆ្ងាយពីគ្នាអីចឹងព្រោះម្នាក់ៗសុទ្ធតែខ្លាចរាងៗខ្លួន
គេមិនបានមកហ៊ានសួរគ្នាទេព្រោះអីកាលនឹងនោះគេនៅតែផ្ទះគេហើយនៅតែស្តាប់តែគ្រាប់គេផ្ទុកផង ស្តាប់យន្តហោះផង
ព្រោះបើគេឃើញថាដូចជាយន្តហោះម៉ូតដូចជាទ្រង់ជ្រូកនឹងផងវាចេះតែហោះទៅហើយថាបើគូទវាឡើងឯចឹងដឹងតែថាវានឹងទំលាក់គ្រាប់បែកទៀតហើយព្រោះគេថាអាយន្តហោះនឹងវាជា

អ្នកយកការណ៍វាមកបើកឡើងពុកទុយៗហើយវាឃើញចឹង
ថាតាមិនស្រួយវាទំលាក់លឺឡើងថុត វានឹងទំលាក់គ្រប់បែកបានមកដល់ថ្លាម
គឺវាបានដាំក្បាលចុះហើយងើបក្បាលឡើងវិញនឹងលឺសូវថាភឹង។
និយាយទៅកាលនឹងអ្នកស្រុកនៅម្តុំជិតយាយនឹងមិនបានហ៊ានទៅណាទេ។
នៅផ្ទះនឹងហើយហូហើយថាអោយទៅសួរនាំហើយទៅសួរសុខទុក្ខគ្នានឹងគឺមិនទេយើងពេល
នឹងដូចជាអ្នកដែលនៅឆ្ងាយនឹងគ្នាអីចឹងដែរនឹង។
និយាយទៅមានរន្ធដៅរាងៗខ្លួនគេជាស្រាច់នៅជិតផ្ទះគេនឹង។

កៈ ចាស!ចឹងកាលនឹងរន្ធដៅមួយនឹងគេជីងប្រហែលជាប៉ុន្មានម៉ែត្រដែលកាលនឹងនោះ?

ខៈ
កាលនឹងគេជីងរន្ធដៅនឹងគេមិនហ៊ានជីកធំទេរន្ធដៅនឹងនោះព្រោះកាលនឹងដឹងថាគេជីកនឹង
មានជំរៅប្រហែលជា៤ម៉ែត្រអីព្រោះកាលនឹងរន្ធដៅត្រសុងនឹងវារាងវែងហើយកាលនឹងគេជីក
ទៅក្នុងដីនឹងរាងចៀក
ថាអានេះនឹងមាត់រន្ធហើយណាហើយអានេះនឹងរន្ធដៅចឹងហើយគេបានជីកអោយវែងចឹងទៅ
ណាអើ
ហើយវាមានផ្លូវឡើងចឹងទៅទៀតចឹងទៅណាហើយបើថាវាមើលទៅមិនសូវស្រួលអីចឹងទៅគេ
រត់ទៅជ្រកហើយ
និយាយទៅរន្ធដៅនឹងគេបានចូលទៅអង្គុយនឹងមួយជូរទៅព្រោះកាលនឹងគេធ្វើនឹងចូលបាន
សំរាប់តែខ្លួន១នាក់តែវារាងវែងហើយកាលនឹងយាយនឹងកំកើតកូនបងគេឈ្មោះភាពហើយ
យាយបានពរភាពនឹងរត់ចូលនៅក្នុងរន្ធដៅនឹងជាមួយគ្នាហើយយាយបានដាក់គេនៅនឹងមុខ
យាយផ្ទាល់យាយដាក់អោយអង្គុយចឹងហោស។
កាលនឹងគេទំលាក់គ្រាប់បែកនឹងបានឆេះផ្ទះមួយហើយយាយបានរត់ទៅច្រកនៅក្នុងរន្ធដៅនឹ
ងដាក់កូនភាពនឹងចឹង អង្គុយចឹង
ហើយវាមកតែម្តងឡើងមានអីពេលនឹងមានវៀតណាមនឹងវាភ័យហើយចឹងក៏វានឹងបានរត់មក
ចូលជាមួយនឹងយើងនៅក្នុងរន្ធដៅនឹងដែលចឹងទៅព្រោះកាលនឹងវាភ័យដែល។

កៈ អូ!!ចឹងកាលនឹងមានជនជាតិវៀតណាមដែរ?

ខ៖
អើ!កាលនឹងមានជនជាតិវៀតណាមមកជាមួយលាយជាមួយនឹងយើងដែរតើវាមកលាយលំជាមួយនឹងយើងហើយកាលនឹងវានឹងភ័យដែលចឹងហើយបានជាវាមករត់ចូលជាមួយនឹងយាយ ហើយចឹងទៅបានជាយាយនឹងនឹកឃើញថាវរវល់ខ្លាចក្រែតែគេឃើញព្រើវានឹងរត់ចូលនៅក្នុងរន្ធដៅនឹងនៅសល់ក្បាលរាងប៉ុមៗដែលព្រោះវាដឹងហើយនោះ
យាយពេលនឹងខ្លាចតែគេមកឃើញហើយទំលាក់មកចំអីនឹងចប់បណ្តោយ។

ក៖ ហាហា!!!

ខ៖ ហើយកាលនឹងយាយទន្ទេរធម៌ដល់ហើយ ..

ក៖ ហាហា!!

ខ៖ ហាហា!!
ហើយចឹងទៅយាយនឹងបានខំអត់ដង្ហើមថាពេលដែលវានឹងទំលាក់នឹងហើយបានជាលឺថាគ្គាំង ហើយនឹងបានថាវារួចហើយវាទៅទំលាក់នៅកន្លែងផ្សេងទេ។

ក៖ ហឺស!!!

ខ៖ ហឺ!!!កាលនឹងយាយនឹងវាវេទនាណាស់កាលនឹងនោះ។

ក៖ ភ័យ?

ខ៖ អើ!!! ...

ក៖ ចឹងកាលនឹងយាយបានចាំទេថាយាយបានរត់ចូលទៅក្នុងរន្ធដៅនឹងបានប៉ុន្មានដងដែល?

ខ៖ កាលនឹងយាយរត់ចូលទៅក្នុងរន្ធដៅនឹងវាកាលនៅពេលគេទំលាក់គ្រាប់បែកទេ ហើយកាលនឹងគេបានទំលាក់គ្រាប់បែកនឹងវាមានយន្តហោះបែប២សណ្ឋានកាលនឹងវាមានយន្តហោះដែលហោះហើយវាហោះនឹងឃ្លាំងមើលថាតើវាគួរតែផ្ទក់ពេលណាហើយថាបើវានឹងចង់ផ្ទក់ហើយនឹងដឹងតែមកហើយគ្រាប់បែកនឹងជូនកាលនៅពេលថ្ងៃរសៀលអីក៏វាមកដែល អោយតែវាចង់
ដល់ចឹងទៅយើងនិងមិនបានដឹងមុនថាតើវានឹងចង់ផ្ទក់នៅពេលណានោះទេដូចនេះហើយបា

នជាយើងនឹងស្តាប់សំលេងលឺសូរថាគ្រឿលថានៅឯណាមើលទៅរាងឆ្ងាយចឹង
ចឹងយើងថាគ្រាប់មកទៀតហើយដល់ចឹងទៅទៅរត់ចូលរន្ធដៅ
មែនស្រាប់ហើយទៅមកមែនពេលដេលវាមកនឹងលឺសំឡេងឡើងវីលីឡើងសូរគ្រាំងចឹងទៅបានជាយើងដឹងថាវាទំលាក់នឹងនៅឯណាឯណោះទេចឹងហើយបានជាយើងនឹងចេញមកវិញ។ កាលជំនាន់នឹងវាវេទនាណាស់កាលជំនាន់នឹងនោះ...

ក៖ ចឹងកាលនឹងវាទំលាក់ច្រើនដងទេនៅក្នុងមួយថ្ងៃកាលនៅជំនាន់នឹងនោះ។

ខ៖ កាលនឹងអានៅនឹងដីក៏វាលឺហើយកាលដែលវាមានយន្តហោះទំលាក់ក៏យើងលឺ
ហើយវាអោយយើងដឹងពីសំលេងរបស់វាលឺឡូងត្រុសៗ
មកស្រាប់តែវាឃើញចឹងវាមានហេតុផលអី ស្រាប់តែវាមានហេតុទេ
វាកើតម៉េចទេបានជាវានឹងទំលាក់គ្រាប់លឺសូរតែផុសចឹងទៅ
ហើយទៅគ្រាប់បែកនឹងវាបានមកដល់ភ្លាមមែន
ព្រោះអោយតែអានឹងវាអោយសញ្ញាណាឡើងលឺថាផុសចឹងនឹងថាវានឹងទំលាក់នៅឯណាទៀតមិនខានទេ។ដាំក្បាលចុះលឺថាខ្ទ័ង
តែដល់ដែលយាយកាលវានឹងបានទំលាក់នៅនឹងបឹងធំទេណាបានមកលឺមកព្រៃកក្រថៅជាកន្លែងដែលយាយនឹងបានមកនៅនឹងហើយវាបានមកងើបនៅនឹងយើងឯនេះឯងអាគ្រាប់យន្តហោះនឹងណា។

ក៖ ងើបនឹងវាយ៉ាងម៉េចដែលទៅលោកយាយ?

ខ៖
ងើបនឹងវាមកធ្លាក់នៅនឹងយើងនឹងណាថៅព្រោះពេលដែលវាទំលាក់នឹងវាទំលាក់នៅនឹងបឹងធំទេប៉ុន្តែវាមកធ្លាក់នៅនឹងយើងឯព្រៃកក្រថៅឯនេះឯ
ហើយកាលនឹងពេលដែលវាទំលាក់នឹងឡើងលឺថាគ្គាំងចឹងហើយវាងើបមកផ្ទុះឡើងពេលពេញនឹងណាថៅយាយ។

ក៖ កាលនឹងយាយបានមើលឃើញ?

ខ៖
អើ!!កាលនឹងនោះយាយដឹងថាវានឹងទំលាក់នៅឯណាទេប៉ុន្តែវាបានរត់មកដល់កន្លែងយើងរស់

នៅនឹងព្រោះកំលាំងអាគ្រាប់បែកនឹងវាខ្លាំងណាស់ហើយលឿនទៀត ហើយពេលដែលរួចហើយនឹងបានជាយើងនឹងទៅមើលទៅឃើញសុទ្ធជាគ្រាប់សំបកច្រើនណាស់ដែលបានបន្សល់ពីការផ្ទុះបែកនឹង ហើយយាយបានឃើញពេលដែលយន្តហោះនឹងវាបើកនៅលើមេឃណាយាយបានឃើញនៅនឹងស្លាបវាឃើញសុទ្ធតែគ្រាប់បែកដែលបំរុងទុកសំរាប់ទំលាក់មកក្រោម។ ហើយមានអាប្រភេទបេណាំមហាយមួយទៀតដែលអានឹងវាសំរាប់ទំលាក់នៅពេលយប់ឡើងថាវានឹងហោះខ្ពស់ណាស់ស្រាប់តែវាមកទំលាក់នៅមាត់ព្រៃកឡើងរួលចឹងទៅ គឺវានឹងឡើងទំលាក់បានត្រូវចំៗនៅនឹងមាត់ទឹកចឹងទៅណា ហើយក៏វានឹងពូកែមែសវានឹងទំលាក់ឡើងចំៗនៅក្បែរមាត់ព្រៃកនៅក្បែរនឹងហើយនៅមាត់ព្រៃកនឹងឡើងពូកែអាបេណាំហៃយនឹងនោះ។

ក៖ កាលនឹងតើវាទំលាក់រកផ្ទះឬរកមនុស្ស?

ខ៖ មិនដឹងថាវានឹងទំលាក់អីទេកាលនឹងអាបេណឹមហៃនឹងនោះ។

ក៖ ចឹងវាចេះតែទំលាក់ទៅកាលនឹងនោះ?

ខ៖ កាលនឹងអាបេណឹមហៃនឹងវាទំលាក់តែនៅតាមផ្ទះទេវាទំលាក់តែពេលយប់ ហើយដល់ពេលដែលវាបានទំលាក់នឹងហើយនឹងគេបានឃើញថាវាដូចជាផាវដែលគេបានដុតចឹងព្រោះសំលេងវាងនឹងឡើងលឺសូរ្យលម៉ង់ហើយ ចឹងបានជាយើងនឹងទៅមើលនៅតាមមាត់ព្រៃវាយប់អីនឹងមិនកើតទេត្រូវតែចូលនៅក្នុងផ្ទះពេលកាលនឹងពេលដែលយើងដេកពពួកអាពតនឹងវានៅក្នុងព្រៃសំរាប់ចូលដេកនឹងធ្វើសកម្មភាពផ្សេងៗចឹងហើយបានជាយាយនឹងប្រាប់ថាអាពួកយន្តហោះនឹងវាតាមទំលាក់នៅតាមផ្លូវមាត់ទឹកហើយក៏បាញ់មកចូលក្នុងព្រៃទាំងសងខាងនៃស្លាបរបស់វានឹង។ ហើយអាបេណាំហៃនឹងពេលដែលវាបានគេបាញ់ហើយវានឹងអោយតែធ្លាក់មកនៅលើដីនឹងដឹងតែមានសំលេងដូចជាភារចឹងដែល ហឺយយ កាលនឹងខ្មែរយើងនឹងវាមិនបាននៅស្រួយទេកាលនឹងនោះវាវេទនាណាស់បើនិយាយទៅនោះ។ ព្រោះកាលនឹងវាបានផុតពីជំនាន់មួយហើយចូលដល់ជំនាន់មួយទៀត ទាល់តែដល់ពេលដែលបានដាច់អាពតនឹងលុនណល់នឹងបានរាងគ្រាន់បើតិចហើយបានបាត់

ភ័យរាងថាវានឹងបានបាត់គ្រាប់បែកនឹងការសំលាប់មនុស្សរបស់ពពតហើយនឹងបានជាយាយនឹងរាងមានក្តីសង្ឃឹមបានបន្តិចដែលកាលនឹងនោះបានដឹងទេថៅកាលនឹងនោះយាយនឹងបានភ័យខ្លាចកាលនៅជំនាន់លន់ណល់នឹងមួយដងហើយតែក្រោយមកនឹងដល់ពេលដែលបានចូលដល់ជំនាន់អាពតហើយមកទៀតយាយមានអារម្មណ៍ភ័យខ្លាំងទៀតហើយព្រោះខ្លាចតែគេហៅចុចយកទៅទេតែល្អដែលចេះបានមានជីវិតរស់នៅដល់សព្វថ្ងៃនេះន៎។

កៈ

ចាសយាយហើយចឹងកាលនឹងតើយាយបានដឹងថាជំនាន់លន់ណល់នឹងបានដាច់ហើយនឹងតាមរយៈ
អ្វីដែលលោកយាយ?ឬក៏យាយបានដឹងដោយសារតែយាយមានវិទ្យុឬក៏បានលឺតគ្នាដែលចឹង?

ខៈ

កាលនឹងបានដឹងថាដាច់នឹងព្រោះពពតដែលបានចូលលាយគ្នានឹងពពួកយាកមិននឹងវាបានឡើងទៅវៃបានភ្នំពេញកាលនឹងនោះហើយវានាំគ្នានឹងលើកទៅវៃងភ្នំពេញនោះកាលនឹងហើយពពួកវាបានវៃឈ្នះចឹងហើយបានជាយាយនឹងដឹងថាអូពពួកអាពតនឹងវាឈ្នះហើយចឹងបានជាផុតជំនាន់លន់ណល់នឹងចូលដល់ជំនាន់អាពតវិញនឹងនោះ។

កៈ ហ៊ឺ!!!

ខៈ

កាលនឹងបានជាដាច់នឹងដែលពេលវាបានចូលទៅដណ្តើមយកទីក្រុងភ្នំពេញបានហើយគេនឹងនាំគ្នាឈ្នះចឹងទៅពួកខាងអាមេរិចអីនឹងវាបានចុះចាញ់វិញចឹងទៅបានជាចឹងនោះថៅអើយហើយចឹងទៅបានជាអាពតនឹងវាក៏បានធ្វើការជំលៀសពួកអ្នកដែលនៅភ្នំពេញនឹងមកស្រុកនឹងតាមតំបន់ឆ្ងាយៗផ្សេងៗដើម្បីអោយធ្វើការនឹងបំបាញ់ជីវៈភាពមិនស្មើគ្នាចឹងពេលដែលគេបាននាំមកនឹងគេប្រាប់ថាអោយមកតែមួយរយៈទេ
តែតាមពិតទៅមកហើយនឹងវាមិនបានអោយទៅវិញអីហើយខ្លះនឹងត្រូវបានគេយកទៅសំលាប់ចោលភ្លាមនឹងខ្លះទៅអ្នកដែលពូកែៗហើយចេះដឹងនឹងមានមុខងារនៅក្នុងជំនាន់នឹងគេបានអោយពពួកគាត់ទៅដាក់នៅនឹងក្នុងគុកទួលស្លែងដែលថៅឯងបានឃើញសព្វថ្ងៃនៅទីក្រុងភ្នំពេញនឹងនោះព្រោះកាលនឹងគេបានធ្វើបានណាស់រហូតទាល់តែស្លាប់។

ក៖
ហើយចឹងពេលដែលលោកយាយដឹងថាដាក់របបអាពតហើយចឹងតើលោកយាយនឹងក្រុមគ្រួសារបានទៅណាដែលឬក៏បានផ្លាស់ទីលំនៅទៅកន្លែងផ្សេងដែរ?

ខ៖
អត់ទេកាលនឹងនោះពេលដែលដាច់ហើយយាយនឹងនៅកន្លែងដដែលទេអត់ទាន់បានផ្លាស់ប្តូរទីលំនៅទៅទីណាឡើយចៅអើយ
តែដល់ពេលក្រោយមកទេដែលយាយនឹងបានចេញមកហើយក៏បានផ្លាស់ទីលំនៅនោះហើយពេលនឹងណាយាយនឹងមានប្តីនឹងគាត់បានស្លាប់ចោលយាយទៅទៀតហើយក៏យាយនឹងបានធ្វើការងាររកស៊ីអាអ្នកលក់នំនៅផ្សារពាមក្នុងនឹងចឹងទៅ។

ក៖
ចឹងមានន័យថាយាយនឹងបានធ្វើការផ្លាស់ប្តូរផ្ទះដែរគឺយាយបានផ្លាស់ប្តូរផ្ទះពីភូមិព្រែកក្របៅមកនៅក្នុងភូមិពាមក្នុងវិញចឹងមែនទេលោកយាយ?

ខ៖
ចាស!ចឹងហើយកាលនឹងយាយបានផ្លាស់លំនៅនឹងមកពីព្រែកក្របៅនឹងមកនៅភូមិពាមក្នុងវិញណាចៅអើយ
កាលនឹងដូចជានៅជំនាន់សាធារណៈរដ្ឋកាលនឹងតែដូចជារដ្ឋកម្ពុជាមិនដឹងកាលនឹងនោះព្រោះកាលនឹងយាយដឹងបានត្រឹមតែលោកហ៊ុនសែននឹងជាអ្នកដែលបានកាន់កាប់កាលនឹងនោះ ឬក៏សាធារណៈរដ្ឋកាលនឹងនោះយាយមិនសូវជាចាំបានច្បាស់នោះទេ។

ក៖ ចាស!!!

ខ៖
ហើយបើនិយាយទៅវាមានរឿងវែងឆ្ងាយណាស់និយាយមិនអស់ទេតែថាកាលនឹងនោះវានៅមិនទាន់បានស្រួលទេរដ្ឋកម្ពុជាអីនឹងនោះនៅមិនទាន់បានមានសេរីភាពពេញលេញនៅឡើយទេស្រួយនឹងទើបតែបានសម្តេចយើងនេះទេដែលលោកបានទៅចចារនៅទីក្រុងប៉ារីសនោះទេបានរាងស្រួលវិញនោះមុននឹងកាលនៅនឹងរដ្ឋកម្ពុជានឹងវានៅរាងតឹងនៅឡើយទេកាលនឹងនោះព្រោះអីកាលនឹងនោះពេលដែលចង់ចេញទៅណានឹងទាល់តែយើងនឹងសុំច្បាប់គេនោះ

បាន
បានព្រោះកានឹងនៅតឹងនៅឡើយកាលសម័យរដ្ឋកម្ពុជានឹងនោះថៅអើយព្រោះកាលនឹងនិយាយទៅបើយើងនឹងចង់ទៅលេងបងប្អូនឬទៅស្រុកក្រៅនឹងត្រូវតែសុំសំប័ត្រអនុញ្ញាតអោយគេធ្វើអោយបើមិនចឹងទេគេមិនអោយយើងនឹងដឹងទេហើយមួយវិញទៀតនឹងគេនឹងមិនអោយយើងនឹងបានដើរចឹងតែម្ដងព្រោះគ្មានសំបុត្រអនុញ្ញាតពីច្បាប់។ហើយមួយទៀតនឹងយាយនឹងថាកាលនឹងវាមិនទាន់មានសេរីភាពនៅឡើយទេព្រោះចង់ទៅណានឹងវាពិបាកដូចជាយាយបានប្រាប់ថៅឯចឹងណាថៅណា។

កៈ តើកាលនឹងយាយបានទៅសុំគេនៅកន្លែងណាដែល?

ខៈ
កាលនឹងយាយត្រូវគេអោយទៅសុំនៅមេប្រធានឃុំគេនឹងហើយក៏ទៅរដ្ឋអំណាចគេនឹងផ្ទាល់ប្រាប់គេថាយើងចង់ទៅលេងនៅស្រុកផ្សេងអីចឹងឬក៏ចង់ទៅលេងបងប្អូនទិញអីវ៉ាន់អីនឹងហើយគេធ្វើសំបុត្រអោយយើងជាមិនខាត
តែគ្រាន់តែយើងនឹងត្រូវចាំហើយមានអារម្មណ៍ថាវាដូចជាមិនមានសេរីភាពនៅក្នុងការធ្វើដំណើរចឹងណាថៅ
ហើយកាលនឹងណានិយាយអោយចំទៅវាគ្មានបានមានសិទ្ធសេរីភាពដូចនៅជំនាន់នឹងទេ
ព្រោះកាលនឹងវាខ្វះសុវត្ថិភាពហើយយើងឥឡូវនឹងវារាងគ្រាន់បើជាងមុនតាំងពីពេលដែលមានការបោះឆ្នោតជ្រើសរើសជានាយករដ្ឋមន្ត្រីសំរាប់ដឹកនាំប្រទេសមកនោះ។
កាលនឹងនោះវាមានច្បាប់ដែលតែវាពិបាកនឹងធ្វើតាមណាស់ព្រោះវានៅរាងតឹងតែងមិនបានសេរីភាពគ្រាប់គ្រាន់ទេថៅ។

កៈ
ចាស!ចឹងមានន័យថាកាលនឹងនោះវាមានច្បាប់ដែលតែនៅមានការរឹតបន្តឹងហើយឥឡូវគឺវាមានលក្ខណៈមានសេរីភពជាងការពីមុនត្រូវទេយាយ?

ខៈ
អើ!!!ត្រូវហើយចឹងវានៅក្នុងច្បាប់ប៉ុន្តែនៅក្នុងច្បាប់គុំមុយន្ទីនៅឡើយនឹងវាមិនសេរីដូចជាជំនាន់ឥឡូវនេះទេឥឡូវនេះគេហៅថាជំនាន់ប្រជាធិបតេយ្យសេរីពហុបក្សចូលរួម

មុននឹងប្រជាធិបតេយ្យដែលប៉ុន្តែវានៅៗ
នៅមានច្បាប់កុំមុយន្ទីនឹងនៅឡើយព្រោះកាលនឹងបើថាធ្វើអ្វីក៏ត្រូវប្រាប់គេអោយបានដឹងដែល។

កៈ ចាស!!!

ខៈ នឹងហើយបើយើងមិនបានសុំច្បាប់គេទេ
គេនឹងថាអោយយើងហើយស្តីអោយយើងមិនមើលមុខទេកាលនឹងអីនឹងព្រោះយើងដើរខុសតំបន់។

កៈ
ចឹងកាលនឹងយាយបានទៅសុំគេឬក៏អត់បានសុំគេហើយគេបានស្តីបន្ទោះអោយលោកយាយ?

ខៈ
កាលនឹងនោះពេលដែលយើងចេញមកខេត្តផ្សេងចឹងគេនៅនឹងហើយយើងនឹងទៅប្រាប់គេហើយសុំគេទៅកាលនឹងមិនទៅលំបាកអីតែគ្រាន់តែវារាងយ៉ាបថាមិនចង់ទៅសុំនឹងព្រោះគ្រាន់តែដើរនៅស្រុកផ្សេងក៏ចាំបាច់ត្រូវទៅដែលយាយមិនចូលចិត្តទេ។

កៈ ចឹងកាលនឹងយាយបានធ្លាប់សុំសំបុត្រអនុញ្ញាតពីគេដែល?

ខៈ
អើ!កាលនឹងមានអីយាយនឹងធ្លាប់សុំគេតើហើយកេបានអោយយាយនឹងទៅតើមើលទៅដូចជាយាយថាចឹងយើងសុំគេអោយណាហើយប្រាប់គេពីមូលហេតុទៅគេនឹងអោយសំប័ត្រហើយណាស់ខ្លាចតែយើងនឹងខ្ជិលមិនទៅសុំគេ
គេនឹងស្តីអោយហើយមានបញ្ហាជាមួយនឹងគេចឹងទៅ
ព្រោះកាលនឹងយើងចាំណាមិនត្រឹមតែឆ្លងស្រុក
ខេត្តអីទេតែគ្រាន់តែឆ្លងភូមិនឹងក៏ត្រូវសុំច្បាប់ពីគេដែលណា។

កៈ អូ!!ចឹងផងគ្រាន់តែភូមិនៅជិតគ្នានឹងក៏សុំដែល?ហេតុអីបានជាគេតំរូវអោយចឹង?

ខៈ អើ!!
ព្រោះវាចៀកកាលនឹងនោះបានជាពេលដែលយើងនឹងដើរគេអោយយើងនឹងទៅសុំសំបុត្រគេ

នឹងដោយសារតែពេលដែលយើងជាអ្នកថ្មីដែលបានដើរឆ្លងកាត់ភូមិគេក៏តំបន់គេចឹងគេត្រូវអោយមានសំបុត្រនឹងហើយគេសង្កេតនឹងសួរសំបុត្រនឹងពីយើងហើយដើម្បីការពារជនមិនស្គាល់ចូលមកក្នុងស្រុងយើងនឹងព្រោះអីកាលនឹងសុវត្ថិភាពវាយ៉ាប់ពេកនឹងហើយមួយទៀតដោយសារការនឹងគេខ្លាចអ្នកដែលមកបន្លំខ្លួនចឹងហើយបានជាគេធ្វើការបែបនឹងនោះហើយបើយើងគ្មានសំបុត្រទេគេនឹងចាប់យើងមិនខានទេ។មានចឹងឯកាលនឹងនោះទើបតែដល់ពេលថ្ងៃ២៣តុលានឹងទេដែលគេបានជាយើងស្រួលឡើងវិញ?

កៈ តើថ្ងៃទី២៣តុលានឹងយ៉ាងម៉េចដែលទៅលោកយាយ?

ខៈ ថ្ងៃទី២៣តុលានឹងសម្តេចយើងនឹងបានទៅរំដោះចេញ
ហើយខំផ្ទើងក្តទៅប្រទេសក្រៅនឹងលីនៅ។

កៈ ចាស!!!

ខៈ
គាត់ថាអោយយើងនឹងឈប់វៃគ្នាទៅព្រោះបើយើងនៅតែវៃគ្នាចឹងវានឹងនៅតែវេទនាទៀតជាមិនខានឡើយព្រោះដឹងទេកាលនៅជំនាន់ដែលបានដាច់ពីអាពតហើយនឹងនៅមាន
ពីព្រោះកាលនឹងគេកេនទៅក៥អីនឹង កាលនឹងគេបានកេនទៅក៥ន់
ហើយពេលនឹងគេកេននឹងមានអ្នកខ្លះទៅគេបានស្លាប់ដោយសារការឈឺស្លាប់អីនឹងនៅនឹងនោះឯង។

កៈ អូ!!!លោកយាយបានដឹងពីប្រវត្តិសាស្រ្តច្រើនណាស់នេះ
ហើយតាមរយៈយាយបាននិយាយប្រាប់នឹងតើលោកយាយបានដឹងតាមរយៈបទពិសោធន៍ឬក៏តាមរយៈកាលមើលសៀវភៅឬតាមរយៈផ្សេងៗទៀត?

ខៈ យី!អានេះនឹងគឺតាមរយៈ យាយបានរៀនមកចេះដឹងទេមកនឹង
ហើយកាលនៅជំនាន់នឹងសម្តេចឪយើងនឹងគាត់បានអោយទៅធ្វើអីដែលកាលនឹងនោះគាត់បានទៅធ្វើគណៈប័ក្សនឹងមួយដែលនឹងហើយចឹងគាត់ក៏បាននាំគ្នាកែនទ័ពចូលទៅក្នុងព្រៃ។

កៈ ចាស!
ចឹងកាលនឹងយាយបានដឹងតពីគ្នាកាលនឹងឬក៏យាយបានដឹងពីណាមកពត័មាននឹង?

ខ៖
ហឺ!មកពីយើងស្តាប់នឹងហើយកាលនឹងវាមានដែលវិទ្យុនោះប៉ុន្តែកាលនឹងនោះក្រោយមកជំនាន់លោកហ៊ុនសែននឹងគេមិនអោយយើងស្តាប់វិទ្យុអាស៊ីសេរីទេណា។

ក៖ ហឺ!!!

ខ៖
នឹងហើយកាលនឹងគេមិនអោយយើងនឹងស្តាប់ពត៍មាននៅស្រុកខ្មែរទេ។ចឹងបានថាច្បាប់ដែលបានផុតពីអាពតមកក៏វានៅតែតឹងនៅឡើយនឹងវាមិនទានបានស្រួលនៅឡើយទេវាមិនមែននៅធូដូចជាយើងសព្វថ្ងៃនឹងទេ។

ក៖ ចាស!!

ខ៖ អើ!ហើយពេលនឹងយាយបានចាំនឹងគឺសម្តាចនឹងបានដើរហៅគ្រាប់១០ប្រទេសហៅកាលនឹងនោះ គាត់គឺជាអ្នកដែលជួយសំរបសំរួលកាលនៅទីក្រុងប៉ារីសនឹងនោះ ថាអោយយើងនឹងឈប់វៃគ្នាទៅព្រោះខ្មែរយើងនឹងទឹមតែងើបពីពពតមកហើយស្លាប់អស់ព្រោះកាលនឹងវាមានមនុស្សស្លាប់នៅក្នុងសម័យពពតនឹងច្រើនដល់ហើយចឹងហើយកាលនឹងក៏សម្តេចយើងនឹងប្រាប់ថាឈប់វៃខ្មែរគ្នាឯងទៅព្រោះទើបតែងើបពីអាពតមកចឹងហើយសូមកុំអោយប្រជាជនខ្មែរនឹងស្លាប់ទៀតអីហើយបានជាមានបណ្តាលប្រទេសផ្សេងៗទៀតជួយសម្របសម្រួលគ្នាទៅហើយនឹងក៏ជួយនិយាយថាឈប់អោយវៃគ្នាទៅបានឈប់កាលនឹងនោះថាពួកអ្នកចូលព្រៃទាំងប៉ុន្មាននឹងអោយចូលមកនៅក្នុងស្រុកវិញទៅហើយនាំគ្នាធ្វើរបបប្រជាធិបតេយ្យវិញទៅ។

ក៖ ហើយក៏មានសេរីភាពវិញទៅ?

ខ៖
អើ!!ចឹងហើយបានជាវានាំគ្នាចូលមកស្រុកនឹងក៏មាននាំគ្នាចូលស្រុកវិញចឹងហើយគេអោយឈរឈ្មោះក៏ឈរទៅព្រោះអ្នកឈរឈ្មោះនឹងពេលដែលរាស្រ្តគេស្រលាញ់គេនឹងបោះឆ្នោតអោយ
ហើយបើអ្នកណាឈ្នះគេនឹងអោយអ្នកនឹងទៅធ្វើជាប្រធាននាធិបតេយ្យទៅហើយចឹងហើយ

បានជាគេមានបានជាជំនួយអ្វីៗមកនឹងណាចឹងហើយនឹងបានជាគេជួយយើងនឹងណាចៅជារាងរៀលឆ្នាំនឹងណាគេយកជំនួយជាច្រើនមកជួយយើងនោះអី។

កៈ
ចាស!ចឹងក្រោយពីបានឆ្លងកាត់បទពិសោធន៍ច្រើនចឹងតើលោកយាយមានបានឆ្លងកាត់ការលំបានអ្វីគេខ្លះដែលលោកយាយនឹកចាំធ្វើអោយលោកយាយមិនអាចនឹងបំភ្លេចបាននោះនៅក្នុងជីវិតរបស់លោកយាយ?

ខៈ អូអារឿងលំបាកនឹងនោះគឺនៅក្នុងជំនាន់អាពតនឹងយាយលំបានខ្លាងណាស់ដល់មែនទែនទៅកាលនឹងនោះវាបានហៅអាទាសសេះមកហៅហើយដាក់មនុស្សយកទៅឡើង
ហើយពេលនឹងគេបានដាក់នាមយើងថាគេពួកប្រជាជនថ្នាក់កណ្តាលចឹងហើយយើងនឹងវាមិនបារភ្ភមិននឹងបាននោះចឹងហើយយាយភ័យណាស់ព្រោះតែយើងមានប្រវត្តិនឹងវាមិនល្អហើយចឹងទៅបានជាយើងខ្លាចហើយអ្នកដែលមានប្រវត្តិល្អនោះគឺពួកអ្នកមានជីវៈភាពក្រីក្រងនោះបានគេថាល្អហើយពួកនឹងមិនសូវបារភ្ភថាគេយកទៅសំលាប់ចោលប៉ុន្មានទេ។

កៈ ចាស!ចឹងយាយបារភ្ភនឹងចាំកន្លែងនឹងជាងគេ?

ខៈ
អើនិយាយទៅយាយបារភ្ភហើយនៅពេលនឹងយាយដេកមិនសូវបានល្អទេហើយលំបាកណាស់កាលនៅជំនាន់អាពតនឹងកាលនឹងនោះហើយកាលនឹងយាយនឹងបារភ្ភជាមួយនឹងវាខ្លាំងណាស់កាលនឹងនោះព្រោះកាលនឹងយាយបាននៅជាមួយនឹងវាហើយមួយទៀតនឹងយាយនឹងអោយតែគេប្រើអីចឹងយាយទៅហើយកាលនឹងនោះព្រោះយាយខ្លាចពួកវានឹងហើយចឹងយើងនឹងត្រូវយកចិត្តទុកដាក់ទៅពេលដែលវាហៅប្រើអីនោះ
ហើយបើនិយាយពីរឿងធ្វើបាបវិញយើងនឹងវាបានធ្វើបាបដល់កហើយនិយាយមិនចង់ចេញទេព្រោះវាឡើងហួសនឹងនិយាយស្តីជាពិសេសអ្នកដែលគេជំលៀសមកពីភ្នំពេញមកនឹងវាលំបាកណាស់ព្រោះពួកនឹងវាជាអ្នកដែលគេត្រូវសំលាប់មុនគេហើយ។

កៈ អូ!!!កាលនឹងយាយបានចាំកន្លែងនឹងដែរ?

ខ៖
និយាយថាមិនចាំយ៉ាងម៉េចបើកាលនឹងយាយបានឃើញផ្ទាល់នឹងភ្នែកតែម្តងនឹងគេយកមនុស្សពីភ្នំពេញនឹងទាំងក្រុមៗហើយដាំអោយធ្វើពលកម្មដូចជាអ្នកដែលមានវ័យពេញកំលាំងដូចថៅឯងចឹងយកទៅអោយរែកដី
ហើយមកដល់ភ្លាមៗនឹងគេយកទៅអោយរែកដីនឹងភ្លាមៗហើយគេយកទៅក្តាប់ថាអោយត្រូវទៅរែកដីនៅឯកន្លែងណាចឹងទៅ។

ក៖ ចាស!!

ខ៖ ហើយទៅកន្លែងណាមានអីគេបានយកទៅសំលាប់ចោលខ្ទិចអីអស់។

ក៖ ចាស!ហើយតើយាយបានជួបនឹងបញ្ហាអ្វីគេដែលនៅក្នុងជីវិតរបស់លោកយាយនឹង?

ខ៖
កាលនឹងវាលំបានណាស់តែដល់ពេលឥឡូវនឹងវាមិនបានជួបនឹងកាលលំបាកអ្វីទេកាលនឹងនោះដូចថាឥឡូវនឹងយើងមានសិទ្ធសេរីភាពហើយកាលមុននឹងយើងគ្មានសិទ្ធសេរីភាពដូចចឹងនោះទេហើយនិយាយទៅវាមិនសូវមានការលំបាកដូចជានៅកាលពីជំនាន់មុននឹងនោះទេ។

ក៖ ចាស!ចំពោះកូនចៅយាយវិញទៅយាយមានការលំបាកអ្វីខ្លះក្នុងការចិញ្ចឹមកូនចៅ?

ខ៖
និយាយពីការចិញ្ចឹមកូនចៅនឹងនិយាយទៅវាលំបាកហើយតែមិនដឹងធ្វើយ៉ាងម៉េចទេធ្វើម៉េចបើយើងនឹងចឹងហើយ
ហើយថាបើយើងនឹងរកបានទៅវាធូហើយតែថាបើយើងនឹងរកមិនបានទេគឺវាពិបាកចឹងទៅណា
វាគ្រាន់តែថាយើងនឹងវាបានល្អហើយមិនដូចជាកាលនៅក្នុងជំនាន់អាពតតានិសតិចនឹងគេយកទៅសំលាប់ចោលហើយ។
និយាយពីការលំបានសព្វថ្ងៃនឹងគឺលំបាកទៅលើការរកស៊ីចិញ្ចឹមជីវិតទេ។

ក៖ ចាស!ចឹងតើលោកយាយមានការលំបាកអ្វីខ្លះនៅក្នុងការចិញ្ចឹមជីវិត?

ខ៖
អាកាលពីមុននឹងយើងរកស៊ីទៅវាស្រួលបានចិញ្ចឹមកូនអីចឹងទៅដល់បានពួកវានឹងធំៗអស់ទៅហើយឥឡូវនឹងកាលលក់ដូរនឹងវាយ៉ាបជាងមុនចាប់ពីត្រឹមនឹងទៅវាគ្មានវាមិនដូចកាលពីដើមទេដូចថាកាលពីមុននឹងវាលក់ទៅដាច់ហើយស្រួលលក់ណាស់តែឥឡូវនឹងវាយ៉ាប់លក់ដូរទៅគេមិនសូវទិញដូចជាលើកមុននោះទេ
បើថាធ្វើចំការដាំដុះអីវាបានផលហើយយកទៅលក់នឹងវាបានថោកណាស់។

ក៖ ចាស! ដូចថាអីឥឡូវនឹងវាមានការសំបូរបែបច្រើន។

ខ៖ អើ!!!ឥឡូវនឹងវាចឹងហើយ។

ក៖
ចាស!ហើយលោកយាយចឹងបន្ទាប់មកចឹងតើលោកយាយមានបទពិសោធន៏ល្អៗអ្វីខ្លះនៅក្នុងជីវិតរបស់លោកយាយដែលលោកយាយបានចាំមកហើយពេលដែលលោកយាយនឹកឃើញវាធ្វើអោយលោកយាយនឹងសប្បាយចិត្ត?

ខ៖
និយាយពីបទពិសោធន៏ស្អីទេសព្វថ្ងៃនឹងនោះបើនិយាយទៅអោយតែខំរកសំរាប់ចិញ្ចឹមជីវិតទេខំប្រឹងធ្វើតែអំពើល្អទៅ។

ក៖ តើយាយធ្លាប់បានរឿងអីដែលធ្វើអោយលោកយាយនឹងសប្បាយចិត្តជាងគេ?

ខ៖ ដែលជួបរឿងអីទេមានតែពេលដែលយើងធ្វើល្អទៅគេតែគេវិញមិនបានធ្វើល្អដាក់យើងវិញយើងចិត្តល្អដាក់គេតែគេនឹង..........ដូចជារឿងដីរបស់យើងនឹងយើងខំចិត្តល្អអោយគេនៅតែគេវិញនឹងគ្មានបានដឹងគុណអីបែរជាពេលដែលគេបាននៅនឹងយូរៗទៅគេក៏ថារបស់គេដល់ចឹងទៅមានបញ្ហានឹងកើតឡើងរហូតបានទៅដល់នៅសាលាឃុំអោយគេជួយដោះស្រាយអោយ។វាពិបាកនឹងមួយទៀតនឹងគឺពេលដែលយើងបានធ្វើល្អហើយនឹងស្រាប់តែគេនឹងបែបជានិយាយមិនល្អដាក់យើងវិញអានឹងក៏មានដែល
ហើយមួយទៀតនឹងគឺយាយអន់ចិត្តមួយទៀតដែលត្រង់ថាពេលដែលយាយនឹងនិយាយទៅជាមួយនឹងគេទៅគេនឹងមិនសូវជាចង់ស្តាប់ទេព្រោះគេបានមើលមកយើងមកវាទន់ជ្រាយព្រោះប្តី

បានស្លាប់ចោលទៅហើយក៏នៅតែម្នាក់ឯងដើម្បីចិញ្ចឹមកូនអានឹងវាចឹងពេលដែលយាយនឹងនិយាយជាមួយនឹងគេទៅគេមិនសូវជាយកចិត្តទុកដាក់ណាអានឹងវាចឹង។

ក៖ ចាស!កាលនឹងពេលដែលអត់ពីកុង។

ខ៖
ហើយមួយទៀតនឹងយាយនឹងក៏នឹកឃើញទៅយាយនឹងក៏មានចិត្តតូចចិត្តនឹងជីវិតដែលថាខំចិញ្ចឹមកូនបាន៧ទៅ៩នាក់ហើយយាយនឹងវាមិនសូវចេះរកនឹងប៉ុនរកដូចគេចឹងហើយយាយនឹងចេះតែគិតច្រើននឹងណា។

ក៖ តើលោកយាយគិតច្រើនទៅលើអ្វីគេខ្លះ?

ខ៖
យាយគិតច្រើននឹងទៅលើកូនចៅដែលគេមានអនាគតយ៉ាងណាទៅបើដូចជាកូនបងឈ្មោះភាពនឹងពេលដែលអត់មានពឹងនឹងទៅជាយ៉ាងណាហើយមួយវិញទៀតដូចកូនចេកអីនឹងបើវាចេះតែឈឺចឹងនោះពេលនឹងពេលដែលអត់ពឹងឯងទៅតើវានឹងយ៉ាងណាហើយពេលដែលទៅពឹងបងប្អូនយ៉ាងម៉េចព្រោះពេលដែលគេមានប្តីនឹងប្រពន្ធគេទៅគេមានលុយគេចិញ្ចឹមតែប្តីនឹងប្រពន្ធកូនគេនឹងវាចឹងត្រូវទេព្រោះអីបើនៅជាមួយនឹង
ឯទៅយ៉ាងម៉េចបើនៅអាមួយឯទៅចឹងនោះពេលដែលរកទៅហើយបានស៊ីសព្វថ្ងៃនឹងទៅតែពេលថ្ងៃអនាគតទៀតនឹងតើវានឹងទៅជាយ៉ាងណាដែល?
វាគ្មានអីទេសព្វថ្ងៃនឹងចឹងហើយបានជាយាយនឹងនឹកឃើញថាត្រូវតែខំធ្វើទានទៅធ្វើអ្វីដែលល្អៗសំរាប់ទុកទៅមុខទៀតព្រោះថាយើងមិនបានដឹងថាពេលដែលទៅមុខទៅវាយ៉ាងម៉េចដូចនេះហើយបានជាយាយនឹងខំទៅធ្វើបុណ្យធ្វើអំពើល្អទុកសំលាប់ស្លាប់ទៅវិញ។

ក៖
តើលោកយាយបានមានការចង់ចាំល្អៗដែលឬទេនៅក្នុងជីវិតរបស់លោកយាយហើយពេលដែលលោកយាយបាននឹកឃើញពីវាធ្វើអោយលោកយាយសប្បាយចិត្ត?

ខ៖
និយាយពីរឿងដែលធ្វើអោយយាយនឹងសប្បាយចិត្តនឹងវាគ្មានទេមានតែរឿងដែលធ្វើអោយយាយមិនសប្បាយចិត្តហើយកើតទុក្ខនឹងហើយព្រោះថាកើតមកជាតិនេះនឹងវាវេទនាកើតមក

មានទុក្ខធ្វើអោយយាយនឹងនឹងទៅចង់ឆ្អែកនឹងជីវិតនឹងហើយមិនចង់ដឹងនឹងយល់ពីវាទៀតទេ ហើយថាព្រោះថាជាតិនឹងវាបានវេទនានោះហើយបានជាជាតិនេះយាយនឹកឃើញថាមានតែកាលធ្វើបុណ្យនោះទេដែលអាចជួយយាយអោយទៅកើតនៅជាតិក្រោយបានល្អជាងជាតិនេះ និយាយទៅកុំអោយយាយនឹងវាវេទនាដូចជាជាតិនេះតទៅទៀតទៅបានហើយ កុំអោយយាយជួបនឹងដូចជាតិនេះតទៅទៀតអានេះជាការគិតរបស់យាយនៅជាតិនេះទេណា បើថាអោយយាយគិតឃើញទៅសប្បាយនោះវាគ្មាននោះទេចៅអើយ គ្មានបានសប្បាយអីនោះទេ។

ក៖
ចុះកាលដែលលោកយាយនៅពីក្មេងមកនឹងតើលោកយាយមានបាននឹកគិតចង់ប្រាថ្នាអ្វីទេពេលដែលលោកយាយធំឡើងនោះ?

ខ៖
យីអារឿងប្រាថ្នានឹងធ្វើម៉េចទេដែលគេថាព្រហ្មលិខិតវាចាលមកវាចឹងហើយនឹងនោះគ្មាននរណាគេចង់ចឹងនោះទេ។

ក៖ ចឹងលោកយាយគ្មានបានប្រាថ្នាអ្វីនោះទេ?

ខ៖
នឹងហើយកាលដែលចង់ប្រាថ្នាអីនឹងបើយើងនឹងវាគ្មានបុណ្យចង់ប្រាថ្នាជាអ្វីក៏ទៅវាមិនរួចដែល។

ក៖
ចាស!ចឹងលោកយាយមិនបានប្រាថ្នាចង់ក្លាយជាអ្វីនោះទេពេលដែលលោកយាយនៅពីក្មេងនោះ?

ខ៖ អាអត់ទេព្រោះយាយបានដឹងថាបើចង់ប្រាថ្នាអីក៏មិនបានដែលព្រោះយើង គ្មានបុណ្យពីជាតិមុនចឹងចង់ប្រាថ្នាអីក៏មិនបានដែលដូចជាថាអោយល្អ អោយសប្បាយចិត្ត ហើយអោយយាយនឹងផុតទោសដូចជាជាតិនឹងមានតែការធ្វើបុណ្យនឹងមួយទេ មានតែផ្លូវកសាងហើយធ្វើបុណ្យទាននឹងតែមួយទេអានឹងហើយដែលគេហៅថាផ្លូវល្អបានសេចក្ដីសុខនោះ។ អានឹងដូចដែលគេថាជាពូជ

បើយើងនឹងដាំពូជបុណ្យកើតទៅមួយជាតិទៀតគឺជាពូជបុណ្យហើយបើយើងនឹងជាពូជបាបវិញនោះយើងកើតមួយជាតិទៀតក៏វានៅតែជាបាបដដែលនឹង
មានលុយមានឡានវីឡាអីស៊ីសំរាប់រស់នៅនឹងមានឡានសំរាប់ជិះហើយលុយសំរាប់ចាយអីនឹងពេលដែលស្លាប់ទៅនឹងមិនអាចយកទៅបានទេទៅវិញនឹងគឺទទេរនឹងអ្នកក្រនឹងក៏ទៅវិញទទេរដូចគ្នាដែលនឹងគ្មានបានយកទៅវិញទេ
គេជាអ្នកមានក៏ស្លាប់ទៅទទេរដូចតែគ្នានឹងគ្មាននរណាម្នាក់គេយករបស់ទាំងអស់នឹងទៅជាមួយបានទេណាចៅ។

ក៖ ចាសចឹងលោកយាយចូលចិត្តស្តាប់បទចម្រៀងដែលឬទេ?
ខ៖ អូបទចម្រៀងគ្មានអីខុសពីបទចម្រៀងរបស់លោកសុនស៊ីសាមុតនោះទេ។

ក៖ ចឹង!យាយមានបាននៅចាំបទចំម្រៀងរបស់គាត់ដែលឬទេ?

ខ៖
គ្មានបានចង់ចាំបទអីទេតែគ្រាន់តែថាបទរបស់គាត់ពេលគាត់បានច្រៀងទៅវាពិរោះគួតែចង់អោយស្តាប់។

ក៖ ចឹង!តើឥឡូវលោកយាយមានបាននៅស្តាប់បទចម្រៀងរបស់គាត់ដែលឬទេ?

ខ៖
នៅតើបទគាត់យាយចូលចិត្តស្តាប់តែក្រៅពីបទរបស់គាត់យាយមិនបានយកចិត្តទុកដាក់ទៅស្តាប់នោះទេ។
វាយាយមិនបានចាំបទគាត់មួយណាទេហើយពេលដែលយាយស្តាប់នឹងក៏យាយស្តាប់លេងៗដែលហើយឥឡូវអីនឹងមិនចូលចិត្តស្តាប់បទចម្រៀងនោះទេសម័យឥឡូវនឹងនោះ
និយាយចឹងទៅដូចមកស្រាប់ហើយដូចជាចៅឯងនឹងបានឃើញស្រាប់ហើយយាយនឹងបានស្តាប់តែធម៌ទេសព្វថ្ងៃនឹងព្រោះអីកាលនឹងយាយនឹងនឹកថាមានតែធម៌ទេដែលអាចជួយយាយបានគ្មានអីទៀតទេឥឡូវនឹងនោះ
ហើយតិចថាពេលដែលក្នុង១ខែអីចឹងយាយនឹងទៅបើស្តាប់ចម្រៀងអីចឹងយាយមិនបានទៅស្តាប់នោះទេ
ព្រោះយាយចូលចិត្តតែស្តាប់លោកគាតទេសព្រោះធ្វើអោយចិត្តយាយនឹងវាបានល្អហើយស

ប្បាយចិត្តពេញចិត្តនឹងជីវិតរបស់ខ្លួនឯង
ចឹងហើយនឹងបានជាយាយនឹងនឹកឃើញថាហេតុអីបានជាយើងនឹងកើតនៅជាមួយនឹងគ្នាមែនពិតបានជាយាយឃើញថាហេតុអីបានជាយាយនឹងកើតមកវាលំបាកហើយគេនឹងវាស្រួលខ្លះទៅគេកើតមកវាមានស្រាប់ហើយខ្លះទៅគេកើតមកក្រលំបាកអានឹងវាអីមកពីជាតិមុននឹងយើងមិនដឹងជាធ្វើស្អីបានជាជាតិនឹងវាមាននិស្ស័យបុណ្យខុសៗគ្នានោះអី
ហើយនិយាយទៅខ្លះទៅគេមានគ្រួសារដែលមានសុភមង្គលនឹងខ្លះទៅគេមានគ្រួសាររកស៊ីមានបានហើយខ្លះទៀតទៅគេក៏បានការដឹងពីសេចក្តីលំបាកវេទនានឹងចឹងហើយវាចឹងតែពេលខ្លះទៅយើងបានឃើញថាមើលទៅគ្រួសារនោះគេមើលទៅដូចជាមានដែលតែហេតុអ្វីបានជាគេនឹងបានឈ្លោះគ្នាចឹងគ្មានបានក្តីសុខចឹងមើលយើងគិតទៅដឹងហើយ
ហើយមួយវិញទៀតគិតមើលហេតុអីគេមានក្តីសុខហើយគ្រួសារផ្សេងទៀតគេគ្មានក្តីសុខចឹងមកពីយើងជាតិមុននឹងពេលដែលយើងកសាងទៅនឹងវាមិនល្អហើយចឹងបានជាចឹងនោះអានឹងយាយដឹងមកតាមរយៈលោកបានទេសចឹងណា។

កៈ
ចាសចឹងហើយតើលោកយាយពេលដែលលោកយាយនៅក្មេងវិញតើលោកយាយចូលចិត្តនឹងលេងល្បែងអីជាងគេ?

ខៈ
លេងល្បែងអីទេកាលនឹងនោះកាលពីដើមនឹងគេពេលដែលចូលឆ្នាំនឹងគេបាននាំគ្នាទៅវត្តទៅលេងបោះអង្គុញអីចឹងទៅ
តែឥឡូវនឹងពេលនឹងយាយចាស់ហើយគ្មានអីមានតែដឹងថាខំសាងអំពើល្អទៅបានហើយដើម្បីទៅមុខទៀត។

កៈ
ហើយចឹងកាលនឹងពេលដែលលោកយាយនឹងក្មេងនឹងលោកយាយបានធ្លាប់លេងល្បែងបោះអង្គុញនឹងចោលឈូងដែលចឹង?

ខ៖ មានអីកាលនឹងយាយធ្លាប់លេងតើតែពេលដែលយាយនឹងមានប្ដីទៅ មានកូនមានអីចឹងទៅមានជាប់កូនចៅចឹងទៅយើងនឹងក៏មានជាប់កូនចៅចឹងទៅបានជាយាយនឹងមិនបានទៅសប្បាយដូចនៅក្មេងឯងណា។

ក៖ ចាស!ហើយឥឡូវនឹងលោកយាយបានរៀបរាប់ប្រាប់ពីបទពិសោធន៍នឹងពង្សប្រវត្តិរបស់លោកយាយច្រើនហើយចឹងតើជាចុងក្រោយតើលោកយាយមានពាក្យពេជ្រអ្វីផ្ដែផ្ដាំដល់ក្មេងៗជំនាន់ក្រោយដែលឬទេ?

ខ៖ គ្មានពាក្យពេជ្រអីទេតែមានតែលោកទេសនាប្រាប់អោយយើងដឹងថាពេលដែលយាយនឹងបានស្ដាប់ហើយនឹងចឹងយាយដឹងតាមគាត់ប្រាប់ថាអោយយើងនឹងខំប្រឹងធ្វើបុណ្យនឹងធ្វើទានទៅកុំទៅច្រណែនគេអោយតែខំធ្វើទានទៅរបស់ដែលគេអោយអីសុំយកកុំទៅគេញប្រវាញ់ញីសឈាមរបស់គេអី អានឹងវាចឹងទេ ហើយពេលដែលយើងរកស៊ីអីចឹងយើងត្រូវតែនិយាយតែពាក្យអីទៀងត្រង់សំរាប់ខ្លួនឯងនឹងអ្នកដទៃកុំទៅកេណ្ឌប្រវាន់គេហើយបោកប្រាស់គេដើម្បីតែរកស៊ីខ្លួនឯងនោះអីយើងត្រូវធ្វើយ៉ាងម៉េចអោយល្អធ្វើតែអំពើល្អៗទៅ ឃើញគេមានទុក្ខមានទោសអីនឹងត្រូវតែជួយគេទៅកុំទៅធ្វើបាបគេអីមានតែប៉ុណ្ណឹង យើងធ្វើល្អនឹងបានមកវិញគឺល្អតែបើថាយើងធ្វើអាក្រក់វានឹងបានមកវិញអាក្រក់ហើយអានឹងវាចឹងអែង។

ក៖ ចាស!ចឹងលោកយាយមានពាក្យបន្ថែមទៀតដែរឬទេឬក៏អស់ហើយ?

ខ៖ អើអស់ហើយ។

ក៖ ចាស!អរគុណលោកយាយថ្ងៃនេះពេលបានចំណាយពេលវេលាសំរាប់អោយខ្ញុំបានសំភាសន៍លោកយាយនៅថ្ងៃនេះ។ ចឹងខ្ញុំសូមការអនុញ្ញាតពីលោកយាយដើម្បីអោយចៅយកសំឡេងរបស់លោកយាយទៅដាក់នៅក្នុងវេបសាយមួយនឹង។

ខ៖ ចាស!!!

ក៖
ចាស!ចឹងសូមអរគុណលោកយាយម្តងទៀតហើយសូមជូនពរអោយក្រុមគ្រួសារមានសុភមង្គលនឹងរកទទួលទានមានបានហើយសូមជូនពរអោយលោកយាយមានសុខភាពល្អនឹងមានព្រះជុនាយុវែង។

ខ៖
ចាស!ចៅសាធុៗសូមអោយចៅអាយុវែងអោយទៅណាទៅនៃអីគេរាប់អានហើយគេស្រលាញ់ហើយអោយជួបតែនាក់ល្អៗអ្នកអាក្រក់អីនឹងកុំអោយជួបអីគឺជួបតែអ្នកដែលល្អៗនៅក្នុងជីវិត។

ក៖ ចាស!សាធុៗសូមអរគុណលោកយាយចាស៕